ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
អគ្គនាយកដ្ឋានរៀបចំដែនដី និងនគរូបនីយកម្ម

# សៀវភៅផែនការរៀបចំដែនដី លេខ ១

# សេចក្តីណែនាំស្តីពីប្រព័ន្ធផែនការរៀបចំដែនដី ក្នុងប្រទេសកម្ពុជា

ខែមិថុនា ឆ្នាំ២០១៦

# សេចក្ដីព្រាង

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

អគ្គនាយកដ្ឋានរៀបចំដែនដី និងនគរូបនីយកម្ម

## សៀវភៅផែនការរៀបចំដែនដី លេខ ១

# សេចក្តីណែនាំស្តីពីប្រព័ន្ធផែនការរៀបចំដែនដី ក្នុងប្រទេសកម្ពុជា

ខែមិថុនា ឆ្នាំ២០១៦

សូមឧទ្ទិសសៀវភៅនេះជូនចំពោះ

លោកបណ្ឌិត Franz-Volker Müller

កើតថ្ងៃទី ០៣ ខែ សីហា ឆ្នាំ ១៩៥០

ទទួលមរណៈភាព ថ្ងៃទី ២២ ខែ មីនា ឆ្នាំ ២០១៥

សម្រាប់ការគាំទ្រអស់ពីកម្លាំងកាយចិត្តដល់ការរៀបចំដែនដី
និងការទទួលស្គាល់សិទ្ធិលើដីធ្លីនៅក្នុងប្រទេសកម្ពុជា

កិច្ចសហប្រតិបត្តិការ អាល្លឺម៉ង់
DEUTSCHE ZUSAMMENARBEIT

គាំទ្រដោយ ៖ GIZ - កម្មវិធីសិទ្ធិលើដីធ្លី II

# បុព្វកថា

ផ្ដើមចេញពីគោលនយោបាយឈ្នះឈ្នះរបស់**សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** ប្រទេសកម្ពុជាទទួលបានសន្តិភាពពេញលេញ មានសន្តិសុខ សុវត្ថិភាព និងស្ថេរភាពនយោបាយល្អ ដែលជាកត្តាមូលដ្ឋានចម្បងនាំឲ្យមានការអភិវឌ្ឍលើគ្រប់វិស័យ ជាមួយនឹងកំណើនប្រជាជនយ៉ាងឆាប់រហ័សដែលកើនឡើងជាង ១៥ លាននាក់។ ដោយប្រជាជនភាគច្រើនរស់នៅពឹងផ្អែកទៅលើកសិកម្ម ទំនាក់ទំនងសង្គមរបស់ពួកគាត់ជាមួយដីធ្លីបានប្រែប្រួលគួរឲ្យកត់សំគាល់ក្នុងរយៈពេលកន្លងមកនាពេលថ្មីៗនេះ។ ចំនួនប្រជាជននៅទីប្រជុំជនមានការកើនឡើងយ៉ាងឆាប់រហ័សជាងចំនួនប្រជាជននៅតំបន់ជនបទ ដែលជាហេតុដែលនាំឲ្យកើនឡើងបញ្ហាប្រឈមចំពោះការបង្កើតការងារ ការផ្ដល់សេវាសាធារណៈ និងការបង្កើតនូវអត្តសញ្ញាណទីប្រជុំជនក្នុងព្រះរាជាណាចក្រកម្ពុជា។

ហេដ្ឋារចនាសម្ព័ន្ធដឹកជញ្ជូន ត្រូវបានធ្វើឲ្យប្រសើរឡើងយ៉ាងឆាប់រហ័ស ហើយវាមិនត្រឹមតែផ្ដល់ និងភ្ជាប់ទៅនឹងរាជធានីនោះទេ ប៉ុន្តែដល់តំបន់ដទៃជាច្រើនទៀតនៅក្នុងព្រះរាជាណាចក្រកម្ពុជា ដែលជួយជម្រុញដល់កំណើនសេដ្ឋកិច្ច និងបង្កើតបណ្ដាញពហុតំបន់ស្នូលរបស់ក្រុង។ លំហូរចលនាអន្តោប្រវេសន៍ឆ្លងកាត់ព្រំដែនទៅបរទេស និងនៅក្នុងស្រុកជាបញ្ហាប្រឈមដល់អភិបាលកិច្ចថ្នាក់ជាតិ និងមូលដ្ឋាន នឹងធ្វើឲ្យមានការប្រែប្រួលដល់ទំនាក់ទំនងរបស់ប្រជាជន និងធនធាននៅលើដីធ្លី។ ក្នុងគោលដៅការពារដល់ធនធានព្រៃឈើ និងធនធានធម្មជាតិដទៃទៀត យើងព្យាយាមខិតខំថែរក្សាការពារបរិស្ថានដែលយើងទាំងអស់គ្នាត្រូវពឹងផ្អែកទៅលើសម្រាប់ការរស់នៅ ដោយធ្វើការថែរក្សាឲ្យស្របទៅនឹងគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព។

ការប្រើប្រាស់ និងមុខងារជាច្រើនរបស់ដី ត្រូវបានគ្រប់គ្រងដោយក្រសួងផ្សេងៗ ហើយក៏ត្រូវបានលើកឡើងនៅក្នុងគោលនយោបាយតាមវិស័យនិងផែនការនានា។ គោលបំណងរបស់ផែនការរៀបចំដែនដី គឺខិតខំព្យាយាមធ្វើឲ្យមានតុល្យភាពរវាងមុខងារ និងការប្រើប្រាស់ដីដែលមានការប្រកួតប្រជែង ព្រមទាំងព្យាយាមផ្ដល់នូវការអភិវឌ្ឍដែនដីប្រកបដោយចីរភាព។ ដូច្នេះរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា តាមរយៈគណៈរដ្ឋមន្ត្រី បានអនុម័តគោលនយោបាយជាតិស្ដីពីការរៀបចំដែនដីនៃព្រះរាជាណាចក្រកម្ពុជានាថ្ងៃទី០៨ ខែមេសា ឆ្នាំ២០១១ និងបានបង្កើតគណៈកម្មាធិការរៀបចំដែនដី និងនគរូបនីយកម្មថ្នាក់ជាតិ ដែលមានក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ជាប្រធាន ដោយគណៈកម្មាធិការនេះជាស្ថាប័នធ្វើការអនុវត្តការកសាងផែនការរៀបចំដែនដី នៅក្នុងព្រះរាជាណាចក្រកម្ពុជា។

ដោយគណៈកម្មាធិការរៀបចំដែនដី និងនគរូបនីយកម្មថ្នាក់ជាតិ និងគណៈកម្មាធិការរៀបចំដែនដី និងនគរូបនីយកម្មថ្នាក់ក្រោមជាតិទើបតែត្រូវបានបង្កើតឡើង ដូច្នេះសបញ្ជាក់យ៉ាងច្បាស់ថា បទពិសោធន៍ដែលមានស្រាប់ដែលទាក់ទងទៅនឹងការកសាងផែនការរៀបចំដែនដី គឺនៅមានកម្រិតនៅឡើយនៅក្នុងព្រះរាជាណាចក្រកម្ពុជា។ នេះជាមូលហេតុយ៉ាងសំខាន់ដែលគណៈកម្មាធិការរៀបចំដែនដី និងនគរូបនីយកម្មថ្នាក់ជាតិ ចាប់ផ្តើមរៀបចំសៀវភៅណែនាំស្តីពីការកសាងផែនការរៀបចំដែនដីនៅថ្នាក់ក្រោមជាតិ ដែលផ្តល់នូវការណែនាំតម្រង់ទិស ដំណើរការជាក់លាក់ និងចំណេះដឹងពីការអនុវត្តការងារជាក់ស្តែង និងការណែនាំដែលផ្អែកទៅលើដំណើរការកសាងផែនការរៀបចំដែនដីដែលបានធ្វើឡើងក្នុងព្រះរាជាណាចក្រកម្ពុជាក្រោមកិច្ចសហប្រតិបត្តិការជាមួយនឹងអង្គការ GIZ ។

សៀវភៅណែនាំនេះត្រូវបានរៀបចំឡើងជាមូលដ្ឋានសម្រាប់អ្នកកសាងផែនការ អនុវត្តន៍តាមជាឯកសារយោង និងធ្វើការផ្លាស់ប្តូរទៅវិញទៅមក។ សៀវភៅណែនាំនេះជាការចូលរួមចំណែកដ៏សំខាន់មួយក្នុងការជួយដល់ក្របខ័ណ្ឌ នៃការកសាងផែនការរៀបចំដែនដីដោយមានការចូលរួម និងជួយដល់ការអភិវឌ្ឍដែនដី នៃព្រះរាជាណាចក្រកម្ពុជាប្រកបដោយចីរភាពនាពេលអនាគត។

ថ្ងៃ...............................ខែ................ ឆ្នាំរកា ព.ស ២៥៦០

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី.......ខែ................ឆ្នាំ ២០១៦

**ទេសរដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និងជា**

**ប្រធានគណៈកម្មាធិការរៀបចំដែនដី និងនគរូបនីយកម្មថ្នាក់ជាតិ**

# មាតិកា


**បុព្វកថា** ..... i

**មាតិកា** ..... iii

**បញ្ជីពាក្យកាត់** ..... iv

**១. សៀវភៅសៀវភៅណែនាំស្តីពីការកសាងផែនការរៀបចំដែនដីថ្នាក់ក្រោមជាតិ៖ សេចក្តីផ្តើម** ..... ១

១.១ សាវតារ ..... ២

១.២ គោលបំណងរបស់សៀវភៅណែនាំ ..... ២

១.៣ ការប្រើប្រាស់សៀវភៅណែនាំ ..... ៣

១.៤ រចនាសម្ព័ន្ធរបស់សៀវភៅណែនាំ ..... ៣

**២. តួនាទីផែនការរៀបចំដែនដីថ្នាក់ក្រោមជាតិ** ..... ៤

២.១ គោលបំណងនៃការកសាងផែនរៀបចំដែនដីថ្នាក់ក្រោមជាតិ ..... ៥

២.២ បញ្ហាប្រឈម និងឱកាសនៃផែនការរៀបចំដែនដីថ្នាក់ក្រោមជាតិ ..... ៥

**៣. ក្របខ័ណ្ឌផែនការរៀបចំដែនដីថ្នាក់ក្រោមជាតិក្នុងប្រទេសកម្ពុជា** ..... ៧

៣.១ ក្របខ័ណ្ឌគោលនយោបាយនិងច្បាប់ ..... ៧

៣.១.១ កំណែទម្រង់ដីធ្លី ..... ៧

៣.១.២ កំណែទម្រង់ការអភិវឌ្ឍតាមបែបលទ្ធិប្រជាធិបតេយ្យ (វិមជ្ឈការ និងវិសហមជ្ឈការ) ..... ៩

៣.២ ក្របខ័ណ្ឌផែនការ ..... ១០

៣.៣ ប្រព័ន្ធផែនការរៀបចំដែនដី ..... ១១

**៤. ទំហំ និងខ្លឹមសាររបស់ផែនការរៀបចំដែនដីថ្នាក់ក្រោមជាតិ** ..... ១៣

៤.១ ផែនការរៀបចំដែនដីថ្នាក់ខេត្ត ..... ១៣

៤.២ ផែនការប្រើប្រាស់ដី និងប្លង់គោលប្រើប្រាស់ដីថ្នាក់ក្រុងនិងស្រុក ..... ១៨

៤.៣ ផែនការប្រើប្រាស់ដីឃុំ/សង្កាត់ ..... ២៤

**៥. គោលការណ៍សំខាន់ៗនៃការកសាងផែនការរៀបចចំដែនដីថ្នាក់ក្រោមជាតិ** ..... ២៨

៥.១ ការកសាងផែនការដោយមានការចូលរួម ..... ២៨

៥.២ ការកសាងផែនការបែបសមាហរណកម្ម ..... ២៩

៥.៣ ផែនការយុទ្ធសាស្ត្រ ..... ៣០

៥.៤ ប្រសិទ្ធភាពផ្នែកច្បាប់នៃផែនការរៀបចំដែនដី ..... ៣០

**៦. ឯកសារយោង** ..... ៣៣

# បញ្ជីពាក្យកាត់

| | |
|---|---|
| CDP | ផែនការអភិវឌ្ឍន៍ឃុំ |
| CDC | ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា |
| CEMAT | សន្និសីទរដ្ឋមន្ត្រីរបស់សហភាពអឺរ៉ុបដែលទទួលខុសត្រូវលើការកសាងផែនការតំបន់/ផែនការរៀបចំដែនដី |
| CMDP | ដៃគូអភិវឌ្ឍន៍រៀបចំសហគមន៍ (អង្គការក្រៅរដ្ឋាភិបាល) |
| CWG | ក្រុមការងារស្នូល (ស្ថិតនៅក្រោមក្រុមការងារថ្នាក់ក្រុងសម្រាប់កសាងផែនការរៀបចំដែនដីថ្នាក់ក្រុង) |
| D&D | ការអភិវឌ្ឍតាមបែបលទ្ធិប្រជាធិបតេយ្យ (ដែលពីមុនហៅថាវិមជ្ឈការ និងវិសហមជ្ឈការ) |
| DED | Deutscher Entwicklungsdienst (សេវាកម្មអភិវឌ្ឍន៍អាល្លឺម៉ង់) |
| DLUMP | ប្លង់គោលប្រើប្រាស់ដីថ្នាក់ស្រុក |
| DP | ផែនការលម្អិត |
| DSDP | ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ស្រុក |
| GIZ | Deutsche Gesellschaft für Internationale Zusammenarbeit GmbH (អង្គការGIZ) |
| ISIC | ចំណាត់ថ្នាក់ឧស្សាហកម្មស្តង់ដារអន្តរជាតិនៃសកម្មភាពសេដ្ឋកិច្ចទាំងអស់ |
| LLMUP | ច្បាប់ស្តីពីការរៀបចំទឹកដី នគរូបនីយកម្ម និងសំណង់ |
| LMUP | ការរៀបចំដែនដី និងនគរូបនីយកម្ម |
| LMUP-C | គណៈកម្មាធិការរៀបចំដែនដី និងនគរូបនីយកម្ម (គ.ដ.ន) |
| LMUP-WG | ក្រុមការងារកសាងផែនការរៀបចំដែនដី និងនគរូបនីយកម្ម |
| LUMP | ប្លង់គោលប្រើប្រាស់ដី |
| LUMP-LUP | ប្លង់គោលប្រើប្រាស់ដី និងផែនការប្រើប្រាស់ដី |
| LRP II | កម្មវិធីសិទ្ធិលើដីធ្លី II (ដោយអង្គការ GIZ) |
| LUP | ផែនការប្រើប្រាស់ដី |
| M&E | ការត្រួតពិនិត្យ និងវាយតម្លៃ |
| MCLMUP | គណៈកម្មាធិការរៀបចំដែនដី និងនគរូបនីយកម្មថ្នាក់ក្រុង (គ.ដ.ន.ក) |
| MIP | កម្មវិធីវិនិយោគក្រុង |
| MLMUPC | ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ (ក្រសួង ដ.ន.ស) |
| MLUMP | ប្លង់គោលប្រើប្រាស់ដីថ្នាក់ក្រុង |
| MoI | ក្រសួងមហាផ្ទៃ |
| MPLUP | ប្លង់គោល និងផែនការប្រើប្រាស់ដី |
| MSDP | ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ក្រុង |

| | |
|---|---|
| MSLWG | ក្រុមការងារគ្រប់គ្រងដីរដ្ឋថ្នាក់ក្រុង |
| NCDD | គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបលទ្ធិប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ |
| NCLMUP | គណៈកម្មាធិការរៀបចំដែនដី និងនគរូបនីយកម្មថ្នាក់ជាតិ (គ.ដ.ន.ជ) |
| NGO | អង្គការក្រៅរដ្ឋាភិបាល |
| NSDP | ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ (រយៈពេល ៥ឆ្នាំ) |
| PCLMUP | គណៈកម្មាធិការរៀបចំដែនដី និងនគរូបនីយកម្មថ្នាក់ខេត្ត (គ.ដ.ន.ខ) |
| PDLMUPCC | មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្ត |
| PIP | កម្មវិធីវិនិយោគសាធារណៈ |
| PSLMC | គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់ខេត្ត |
| PSP | ផែនការរៀបចំដែនដីថ្នាក់ខេត្ត |
| RGC | រាជរដ្ឋាភិបាលកម្ពុជា |
| SFT | ក្រុមការងារសង្កាត់ |
| SNEC | ឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ |
| SWOT | ភាពខ្លាំង ភាពខ្សោយ ឱកាស និងការគំរាមកំហែង |

## ១.សៀវភៅណែនាំស្ដីពីការកសាងផែនការរៀបចំដែនដីថ្នាក់ក្រោមជាតិៈ សេចក្ដីផ្ដើម

ប្រព័ន្ធផែនការរៀបចំដែនដីនៅក្នុងប្រទេសកម្ពុជា ចែកចេញជាផែនការកម្រិតថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិដែលរួមមានខេត្ត(និងរាជធានី) ក្រុង(និងខណ្ឌ) និងស្រុករួមទាំងឃុំនិងសង្កាត់ផងដែរ។ ទោះបីជាមានបទពិសោធន៍ជាក់ស្ដែង ក៏ដូចជាគោលការណ៍ណែនាំសម្រាប់ការកសាងផែនការប្រើប្រាស់ដីថ្នាក់ឃុំ ប៉ុន្តែសម្រាប់ការកសាងផែនការថ្នាក់ក្រោមជាតិពីរផ្សេងទៀត គឺមានបទពិសោធន៍តិចតួចតែប៉ុណ្ណោះ។ ដោយមានការគាំទ្រពីអង្គការ GIZ ខេត្តពីរបានចាប់ផ្ដើមគម្រោងសាកល្បងកសាងផែនការរៀបចំដែនដីថ្នាក់ខេត្ត ហើយក្រុងចំនួនបួននិងស្រុកពីរទៀតបានចាប់ផ្ដើមកសាងប្លង់គោលប្រើប្រាស់ដី។ បទពិសោធន៍ពីដំណើរកសាងផែនការទាំងនេះ បានចូលរួមចំណែកជួយគាំទ្រដល់ការបង្កើតសៀវភៅណែនាំស្ដីពីការកសាងផែនការរៀបចំដែនដីនេះ។ សៀវភៅណែនាំនេះ មានគោលបំណងផ្ដល់នូវដំណើរការដ៏ច្បាស់លាស់មួយ រួមទាំងអនុសាសន៍ និងចំណេះដឹងពីការអនុវត្តជាក់ស្ដែងដល់អ្នកដែលនឹងត្រូវទទួលបន្ទុកចូលរួមក្នុងដំណើរការកសាងផែនការរៀបចំដែនដីនាពេលអនាគត។

សៀវភៅណែនាំនេះ មានគោលបំណងផ្ដល់នូវបទដ្ឋានស្ដង់ដារួមមួយសម្រាប់ដំណើរការរៀបចំផែនការផ្សេងៗ ដូច្នេះវាអាចជួយគាំទ្រដល់ការចូលរួមប្រកបដោយប្រសិទ្ធភាព ការវិភាគ និងការធ្វើផែនការតាមលក្ខណៈបច្ចេកទេស ក៏ដូចជាផ្ដល់ជាជំនួយផ្នែកស្ថាប័នដល់ក្រុមការងារកសាងផែនការជាច្រើន ដែលមិនទាន់ចាប់ផ្ដើមការកសាងផែនការរៀបចំដែនដីសម្រាប់ដែនដីរបស់ខ្លួន។ សៀវភៅណែនាំនេះ មិនមែនជាសៀវភៅក្បួនបណ្ដុះបណ្ដាលនោះទេ ប៉ុន្តែវាចូលរួមចំណែកដល់ការកសាងសមត្ថភាពសម្រាប់ការកសាងផែនការរៀបចំដែនដីថ្នាក់ក្រោមជាតិ ដែលមានភ្ជាប់ជាមួយនូវឧទាហរណ៍ជាច្រើន រួមទាំងការពន្យល់យ៉ាងច្បាស់លាស់ពីជំហាន និងការងារដែលនឹងត្រូវអនុវត្តសម្រាប់ផែនការរៀបចំដែនដី។

ដំណើរការកសាងផែនការនៃគម្រោងសាកល្បងដែលបង្ហាញនៅក្នុងសៀវភៅនេះ ត្រូវបានគាំទ្រពីទីប្រឹក្សាខាងក្រៅ ដែលបានធ្វើការងារជាមួយនឹងដំណើរការ និងក្រុមការងារកសាងផែនការចាប់តាំងពីចាប់ផ្ដើមការងាររហូតដល់បញ្ចប់។ សៀវភៅណែនាំនេះ ត្រូវបានបង្កើតឡើងដែលឆ្លើយតបដោយផ្ទាល់ដល់មន្ត្រីធ្វើផែនការរបស់គណៈកម្មាធិការកសាងផែនការរៀបចំដែនដី និងក្រុមការងារ ប៉ុន្តែការផ្ដល់ដំបូន្មាន (អនុសាសន៍) ពីខាងក្រៅ គឺតែងតែមានសារៈប្រយោជន៍ ហើយពេលខ្លះវាមិនអាចជៀសផុតនោះទេ។ ដើម្បីឲ្យវាអាចអនុវត្ត និងអាចបត់បែនបាន តម្រូវការនិងជម្រើសផ្សេងៗដែលឆ្លើយតបទៅនឹងបញ្ហាកង្វះសមត្ថភាពត្រូវបានលើកឡើងនៅក្នុងសៀវភៅណែនាំនេះ។

## ១.១ សារតារ

ការកសាងផែនការរៀបចំដែនដីសំដៅដល់វិធីសាស្ត្រ និងឧបករណ៍ដែលប្រើប្រាស់ដោយអង្គភាពរដ្ឋ (វិស័យសាធារណៈ) ដើម្បីមានឥទ្ធិពលក្នុងការគ្រប់គ្រងរបាយប្រជាពលរដ្ឋ និងសកម្មភាពផ្សេងៗនៅលើដែនដីក្នុងមាត្រដ្ឋានផ្សេងៗគ្នា។ វាជាឯកសារដែលជួយដល់អ្នកធ្វើសេចក្តីសម្រេចចិត្តក្នុងការធ្វើសេចក្តីសម្រេចចិត្តផ្សេងៗក្នុងដែនដីរបស់ខ្លួន សម្រាប់ការអភិវឌ្ឍដែនដីនាពេលអនាគត ៖ ការគ្រប់គ្រងការប្រើប្រាស់ដី ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធសង្គមនិងរូបវន្ត ការការពារធនធាន។ល។ ការកសាងផែនការរៀបចំដែនដី ត្រូវបានទទួលស្គាល់ជាបន្តបន្ទាប់ថាជាកិច្ចការមួយដ៏ចាំបាច់សម្រាប់ការអភិវឌ្ឍប្រកបដោយចីរភាព។

ផែនការរៀបចំដែនដីមានជាយូរណាស់មកហើយ ប៉ុន្តែផែនការនេះគឺថ្មីសម្រាប់ប្រទេសកម្ពុជា។ ស្របគ្នាជាមួយនឹងគោលនយោបាយលើកស្ទួយវិមជ្ឈការនយោបាយ និងវិសហមជ្ឈការរដ្ឋបាលដែលបានបង្កើតឡើងក្នុងដើមទសវត្សរ៍ឆ្នាំ ២០០០ ព្រះរាជាណាចក្រកម្ពុជាបានបង្កើតគោលនយោបាយ និងឯកសារផ្លូវច្បាប់ដែលជាមូលដ្ឋានគ្រឹះ សម្រាប់ការកសាងផែនការរៀបចំដែនដីថ្នាក់ក្រោមជាតិ (ខេត្ត ស្រុក និងក្រុង)។ ច្បាប់ អនុក្រឹត្យសម្រាប់ការអនុវត្ត និងដំណើរការលម្អិតសម្រាប់កសាងផែនការរៀបចំដែនដីត្រូវបានធ្វើសេចក្តីព្រាង ហើយផ្នែកខ្លះបានអនុម័តដើម្បីគាំទ្រដល់ការកសាងផែនការរៀបចំដែនដីថ្នាក់ក្រោមជាតិមានថ្នាក់ខេត្ត ថ្នាក់ស្រុក និងថ្នាក់ក្រុង។

សៀវភៅផែនការរៀបចំដែនដីជាស៊េរីនេះរួមមានសៀវភៅណែនាំសំខាន់ៗចំនួនបី។ សៀវភៅទី១ ស្តីអំពីសេចក្តីផ្តើមដែលបង្ហាញពីតួនាទី ក្របខ័ណ្ឌស្ថាប័ន គោលការណ៍សំខាន់ៗ និងទំហំនៃការកសាងផែនការរៀបចំដែនដីថ្នាក់ក្រោមជាតិ។ សៀវភៅទី២ ស្តីពីដំណើរការកសាងផែនការរៀបចំដែនដីថ្នាក់ខេត្ត និងសៀវភៅទី៣ស្តីពីប្លង់គោលប្រើប្រាស់ដីថ្នាក់ក្រុងនិងស្រុក។ សៀវភៅទី៣នេះ ក៏មានបញ្ចូលនូវការកសាងផែនការប្រើប្រាស់ដីថ្នាក់ក្រុង និងស្រុក និងមជ្ឈមណ្ឌលទីប្រជុំជនរបស់ស្រុក។

## ១.២ គោលបំណងរបស់សៀវភៅណែនាំ

សៀវភៅណែនាំស្តីអំពីការកសាងផែនការរៀបចំដែនដី មានគោលបំណងផ្តល់នូវការណែនាំតម្រង់ទិសក្នុងការបង្កើតផែនការរៀបចំដែនដីថ្នាក់ក្រោមជាតិ ដើម្បីធ្វើឲ្យប្រសើរឡើងដល់គុណភាពរបស់ផែនការនេះ និងជាមូលដ្ឋានសម្រាប់កសាងសមត្ថភាពរបស់អ្នកធ្វើផែនការរៀបចំដែនដីនៅក្នុងប្រទេសកម្ពុជា។ សៀវភៅណែនាំនេះ ក៏នឹងត្រូវប្រើប្រាស់ជាឯកសារយោងដែលអាចជួយដល់អ្នកធ្វើផែនការរៀបចំដែនដី (មន្ត្រីផែនការ ក៏ដូចជាអ្នកបណ្តុះបណ្តាល និងទីប្រឹក្សា) ក្នុងការធ្វើផែនការរៀបចំដែនដីជាក់ស្តែង និងជួយដល់អាជ្ញាធរក្នុងការធ្វើសេចក្តីសម្រេចចិត្ត។ វាផ្តល់ និងបំពេញបន្ថែមដល់

ដំណើរការកសាងផែនការផ្លូវការដែលអនុម័តដោយក្រសួង ដោយបង្ហាញពីជំហាននៃដំណើរការកសាងផែនការជាមួយនឹងការងារសំខាន់ៗដែលនឹងត្រូវអនុវត្ត និងបង្កើតនូវលទ្ធផលតាមក្តីប្រាថ្នា។ សៀវភៅណែនាំនេះត្រូវបានចាត់ទុកជាឯកសារយោងដែលមានភាពងាយស្រួលក្នុងការពិភាក្សាសម្រាប់ការតម្រង់ទិសដល់ដំណើរការកសាងផែនការរៀបចំដែនដី។ វាជួយពង្រឹងការយល់ដឹង និងភាពច្នៃប្រឌិតរបស់អ្នក កសាងផែនការដើម្បីឆ្លើយតបទៅនឹងលក្ខណៈពិសេសរបស់តំបន់ដែលនឹងត្រូវធ្វើផែនការ។

## ១.៣ ការប្រើប្រាស់សៀវភៅណែនាំ

ការធ្វើសេចក្តីព្រាងសៀវភៅនេះ បានចាប់ផ្តើមធ្វើឡើងក្នុងខណៈពេលដែលការកសាងផែនការរៀបចំដែនដីនៅមានភាពក្មេងខ្ចីនៅឡើយនៅក្នុងប្រទេសកម្ពុជា។ សមត្ថភាពដែលមានស្រាប់ និងឱកាសរៀនសូត្រពីការកសាងផែនការរៀបចំដែនដីនៅមានកម្រិតនៅឡើយ ជាពិសេសនៅថ្នាក់ក្រោមជាតិ។ ដូច្នេះហើយ សៀវភៅណែនាំជាសេរីនេះ មិនមែនជាសៀវភៅមេរៀនផ្នែកទ្រឹស្តីនោះទេ ប៉ុន្តែវាជាសៀវភៅដែលផ្តល់នូវភាពសាមញ្ញ (ងាយស្រួល) ដែលមានអត្ថន័យពេញលេញក្នុងការកសាងផែនការរៀបចំដែនដីតាមវិធីសាស្ត្រសាមញ្ញមួយជំហានម្តងៗ។ វាអាចនឹងត្រូវការគាំទ្រពីខាងក្រៅបន្ថែម ប៉ុន្តែភាគច្រើនសម្រាប់ការកសាងសមត្ថភាពរបស់ក្រុមការងារក្រុង ស្រុក និងខេត្ត ដែលត្រូវបណ្តុះបណ្តាលឲ្យល្អប្រសើរដើម្បីអនុវត្តនូវជំហាន និងការងារសំខាន់ៗ ដែលបានលើកឡើងនៅក្នុងសៀវភៅនេះ។

សមាសភាគសំខាន់ៗដែលបានលើកឡើងនៅក្នុងសៀវភៅនេះគឺ ការគ្រប់គ្រងដីថ្នាក់ស្រុក ក្រុង និងខេត្ត គណៈកម្មាធិការរៀបចំដែនដី និងក្រុមការងារ។ បន្ថែមពីនេះទៀត វាក៏បានលើកឡើងពីការរៀបចំដែលជួយគាំទ្រដល់ដំណើរការកសាងផែនការរៀបចំដែនដី ក៏ដូចជាមន្ត្រីរដ្ឋាភិបាលមកពីវិស័យពាក់ព័ន្ធសំខាន់ៗ ជាពិសេសមន្ត្រីទាំងឡាយណាដែលទទួលបន្ទុកក្នុងការកសាងផែនការអភិវឌ្ឍន៍រយៈពេល៥ឆ្នាំ។ ជាចុងក្រោយនេះ វាក៏ជាឯកសារតម្រង់ទិសសម្រាប់អ្នកពាក់ព័ន្ធផ្សេងៗទៀតក្នុងការស្វែងយល់ពីទស្សនទាន សមត្ថកិច្ច និងយន្តការនៃការកសាងផែនការរៀបចំដែនដី។

## ១.៤ រចនាសម្ព័ន្ធរបស់សៀវភៅណែនាំ

សៀវភៅណែនាំអំពីការកសាងផែនការរៀបចំដែនដីថ្នាក់ខេត្តមាន ៦ ជំហានសំខាន់ៗ ដែលជំហាននីមួយៗមានការងារមួយចំនួនដែលត្រូវអនុវត្ត ហើយការងារនីមួយៗមានរៀបរាប់លម្អិតពីវិធីសាស្ត្រ/សកម្មភាព អ្នកចូលរួម ធាតុចូល ឧបករណ៍ និងលទ្ធផលតាមក្តីប្រាថ្នា។ វាក៏លើកឡើងពីសុច្ឆនាករកំណត់ពេលសម្រាប់ការងារនីមួយៗផងដែរ។ ជាទូទៅ វារួមមានការរៀបចំ ឬដំណាក់កាល

ចាប់ផ្តើម ការរៀបរាប់ពីការវិភាគស្ថានភាពដ៏ទូលំទូលាយមួយ និងបន្ទាប់មកទៀតមានការព្យាករណ៍ ឬការស្មើឡើងនៃការអភិវឌ្ឍនាពេលអនាគតតាមក្តីប្រាថ្នា ដែលត្រូវបានបំពេញបន្ថែមដោយយុទ្ធសាស្ត្រដែលផ្សារភ្ជាប់ទៅនឹងស្ថានភាពបច្ចុប្បន្ន និងការអភិវឌ្ឍនាពេលអនាគតទាំងនោះ។ ហើយក៏មានការងារផ្សេងៗសម្រាប់ជំហានទាំងនោះ ដើម្បីគាំទ្រដល់ការអនុវត្តដល់ផែនការ និងដំណើរការអនុម័តចុងក្រោយ។

សៀវភៅណែនាំទី៣ ស្តីពីការកសាងប្លង់គោលប្រើប្រាស់ដីថ្នាក់ក្រុង និងស្រុក និងផែនការប្រើប្រាស់ដីមានរចនាសម្ព័ន្ធដូចគ្នា ទោះបីជាចំនួនជំហានសម្រាប់ប្លង់គោលប្រើប្រាស់ដី និងផែនការប្រើប្រាស់ដីទាំងពីរនេះ បានធ្វើឲ្យស្របទៅនឹងនីតិវិធីលម្អិតដែលត្រូវបានរៀបចំឡើងសម្រាប់កសាងផែនការប្រើប្រាស់ដី និងប្លង់គោលប្រើប្រាស់ដីនៅថ្នាក់ក្រុង ស្រុក ខណ្ឌ (គ.ជ.ន.ជ ២០១៣។ ចំណុចពិសេសនៃសៀវភៅទី៣នេះ គឺលើកឡើងពីវិធីសាស្ត្រកសាងផែនការតាមបែបសមាហរណកម្មសម្រាប់ថ្នាក់ក្រុងនិងស្រុក។ ជម្រើសនេះគឺមានហេតុផលផ្សេងៗ។ ដោយការប្រើប្រាស់ដីនៅក្នុងក្រុងនិងស្រុកនីមួយៗនៅក្នុងប្រទេសគឺមិនមែនសុទ្ធតែជាជនបទ ឬសុទ្ធតែជាទីប្រជុំជននោះទេ។ វាមានការប្រើប្រាស់ដីចម្រុះគ្នារវាងទីប្រជុំជន និងជនបទ ដូច្នេះទំនាក់ទំនងនៃការប្រើប្រាស់ដីទាំងនេះមានសារៈសំខាន់ណាស់ ហើយគុណភាពនៃការប្រើប្រាស់គឺមានការប្រែប្រួលពីកន្លែងមួយទៅកន្លែងមួយ។ ចំណុចសំខាន់រួម និងវិធីសាស្ត្រកសាងផែនការរៀបចំដែនដីជាក់លាក់ត្រូវធ្វើការឆ្លើយតបទៅនឹងតំបន់ទីប្រជុំជននិងតំបន់ជនបទ ប៉ុន្តែត្រូវមានអន្តរអំពើនិងឥទ្ធិពលរវាងគ្នាទៅវិញទៅមក។ ទំនាក់ទំនងទាំងនេះជាចំណុចស្នូល (បេះដូង) នៃការកសាងផែនការរៀបចំដែនដី ហើយវាជាហេតុផលមួយនៃមូលហេតុដែលសៀវភៅនេះធ្វើសមាហរណកម្មជាមួយនឹងដំណើរការនិងវិធីសាស្ត្រកសាងប្លង់គោលប្រើប្រាស់ដី។ ដោយប្លង់គោលប្រើប្រាស់ដី ជាអ្នកដាក់កម្រិត និងតម្រង់ទិស (ជាឯកសារយោង) ដល់ផែនការប្រើប្រាស់ដី ដូចនេះដំណើរការសម្រាប់ផែនការប្រើប្រាស់ដី (ទីប្រជុំជន) ត្រូវបានបញ្ចូលទៅក្នុងសៀវភៅនេះយ៉ាងសមហេតុសមផល ដែលជាកិច្ចការបន្តពីដំណើរការកសាងប្លង់គោលប្រើប្រាស់ដី។

## ២. តួនាទីផែនការរៀបចំដែនដីថ្នាក់ក្រោមជាតិ

គោលបំណងនៃការកសាងផែនការរៀបចំដែនដី គឺដើម្បីធ្វើសមាហរណកម្មការប្រើប្រាស់ដីផ្សេងៗគ្នា (ពេលខ្លះជាការប្រកួតប្រជែងលើការប្រើប្រាស់ដ៏សមស្រប) ដើម្បីឆ្ពោះទៅកាន់ការរៀបចំដែនដីរូបវន្ត និងការអភិវឌ្ឍដែនដីប្រកបដោយគុណភាព (CEMAT2007)។ ការកសាងផែនការរៀបចំដែនដី គឺជាកិច្ចការងារដែលតែងតែមានការគាំទ្រពីវិស័យសាធារណៈ (រដ្ឋបាលដែនដី) ដែលវាបម្រើជាឯកសារយោងសម្រាប់អ្នកដែលធ្វើការងារពាក់ព័ន្ធ ឬចាប់អារម្មណ៍ទៅនឹងការអភិវឌ្ឍដែនដីដូចជា ៖ ប្រជាពលរដ្ឋ និងអង្គការ សហគមន៍របស់គាត់ ស្ថាប័នរដ្ឋ ដៃគូអភិវឌ្ឍន៍ និងវិស័យឯកជន។

## ២.១ គោលបំណងនៃការកសាងផែនរៀបចំដែនដីថ្នាក់ក្រោមជាតិ

នៅក្នុងបរិបទនៃការអភិវឌ្ឍសេដ្ឋកិច្ចសង្គម និងនគរូបនីយកម្មយ៉ាងឆាប់រហ័ស ការកសាងផែនការរៀបចំដែនដី គឺជាដំណើរការដ៏សំខាន់ដែលអាចដោះស្រាយដល់បញ្ហាប្រឈម និងប្រយោជន៍ផ្សេងៗ ឱកាសអភិវឌ្ឍន៍ដែលមានស្រាប់ និងកំពុងកើតមាន។ ការកសាងផែនការរៀបចំដែនដីត្រូវបានចាត់ទុកជាដំណើរការមួយដែលចូលរួមដល់ការអភិវឌ្ឍប្រកបដោយចីរភាពដើម្បី ៖

- លើកស្ទួយប្រសិទ្ធភាពសេដ្ឋកិច្ច ៖ ធ្វើឲ្យប្រសើរឡើងដល់ប្រសិទ្ធភាពសេដ្ឋកិច្ច បង្កើតនូវតម្លៃ និងគុណប្រយោជន៍បន្ថែមដល់វិស័យសេដ្ឋកិច្ចទាំងអស់ និងលើកស្ទួយដល់កម្រិតជីវភាពរស់នៅ។
- ធានាដល់យុត្តិធម៌សង្គមនិងការមិនរើសអើង ៖ ដោយធានាដល់ការបំពេញតម្រូវការរបស់ប្រជាពលរដ្ឋទាំងអស់នាពេលបច្ចុប្បន្ន និងពេលអនាគត និងកាត់បន្ថយនូវគម្លាតសង្គមរវាង និងនៅក្នុងតំបន់។ នេះទាមទារនូវការយកចិត្តទុកដាក់យ៉ាងសំខាន់ទៅលើក្រុមដែលងាយរងគ្រោះបំផុតនៅក្នុងសង្គម និងការទទួលបាននូវហេដ្ឋារចនាសម្ព័ន្ធ និងសេវាសាធារណៈមូលដ្ឋាន ។
- ធានាដល់ចីរភាពបរិស្ថាន ៖ ការពារធនធានធម្មជាតិដែលមានសារៈសំខាន់សម្រាប់និរន្តរភាព និងផលិតភាពរបស់ដែនដី និងជួយដល់ការប្រើប្រាស់ធនធានធម្មជាតិស្របទៅតាមសមត្ថភាពនៃការកើតឡើងវិញរបស់ធនធានទាំងនោះ។
- ការពារអត្តសញ្ញាណវប្បធម៌ ៖ ការពារកេរតំណែល វប្បធម៌ សំណង់ ឬទេសភាពវប្បធម៌ធម្មជាតិដែលមានតម្លៃមិនអាចកាត់ថ្លៃបានសម្រាប់ប្រជាពលរដ្ឋមូលដ្ឋាន។

## ២.២ បញ្ហាប្រឈម និងឱកាសនៃផែនការរៀបចំដែនដីថ្នាក់ក្រោមជាតិ

ប្រព័ន្ធប្រើប្រាស់ដីដែលបង្កើតជាមូលដ្ឋានសម្រាប់សុវត្ថិភាពស្បៀង និងការអភិវឌ្ឍសេដ្ឋកិច្ចនៅក្នុងប្រទេសកម្ពុជាមានការប្រែប្រួលយ៉ាងខ្លាំងក្នុងរយៈពេលប៉ុន្មានទសវត្សរ៍ចុងក្រោយនេះ។ ដោយរងនូវឥទ្ធិពលកំលាំងចលករសង្គម នយោបាយ និងអេកូឡូស៊ី ការប្រែប្រួលទាំងនេះនាំឲ្យមានដំណើរការផ្សេងៗដែលមានអន្តកម្មរវាងគ្នាទៅវិញទៅមកក្នុងកម្រិតផ្សេងៗគ្នា៖

- ត្រូវបានធ្វើរបាយការណ៍ស្តីពីការកាប់ព្រៃឈើក្នុងកម្រិតខ្ពស់ (Hansen et al. 2013; Save Cambodia's Wildlife 2014) ក៏ដូចជាការសឹករេចរឹលដីដែលកើតមកពីការអភិរក្សដីមានភាពទន់ខ្សោយ (Bai et al. 2008; Seng 2014) និងការថយចុះបរិមាណជលផល និងទិន្នផលជលផលក្នុងអ្នកនេសាទម្នាក់ (Baran 2005)។
- មានចលនានៃការពង្រីកកសិកម្មយ៉ាងខ្លាំង ពីតំបន់វាលស្រែទំនាបទៅតំបន់ខ្ពង់រាប ដោយមានទំនាក់ទំនងទៅនឹងអន្តោប្រវេសន៍ពីតំបន់ទំនាបទៅតំបន់ខ្ពង់រាប (Diepart, Pilgrim, and Dulioust

2014) ហើយវាបានចូលរួមចំណែកដល់ការធ្វើឲ្យមានរបាយប្រជាពលរដ្ឋនៅក្នុងតំបន់នោះ ដូចដែលមាននៅក្នុងប្រទេសកម្ពុជាទាំងមូល ហើយវាក៏បង្កើតនូវតម្រូវការថ្មីសម្រាប់ហេដ្ឋារចនាសម្ព័ន្ធសង្គម និងរូបវន្ត។

- មានប្រព័ន្ធកសិកម្មចម្រុះសម្រាប់ដំណាំឆ្លងកាត់និងដំណាំយុទ្ធសាស្ត្រ ដែលវាជាលទ្ធផលដែលកើតចេញពីទីផ្សារថ្មីសម្រាប់កសិកម្ម។ មានទម្រង់អភិវឌ្ឍកសិកម្មថ្មីកំពុងកើតមានឡើងដែលពឹងផ្អែកយ៉ាងខ្លាំងទៅលើការវិនិយោគខ្នាតធំមកពីខាងក្រៅ ដែលឥឡូវវាមានលាយឡំគ្នាជាមួយការធ្វើកសិកម្មតាមគ្រួសារ ហើយវាជាទូទៅតែងតែមានបញ្ហាទំនាស់ផ្សេងៗ។
- នគរូបនីយកម្មកំពុងតែចាក់ឫសនៅក្នុងប្រទេសកម្ពុជា ៖ កំណើនប្រជាជននៅក្នុងមជ្ឈមណ្ឌលទីប្រជុំជន មានការកើនឡើងយ៉ាងឆាប់រហ័ស ហើយការរីកនៃតំបន់នគរូបនីយកម្ម គឺដើរទន្ទឹមជាមួយកំណើនតម្រូវការសេវាកម្ម លំនៅឋាន និងការងារ។ នគរូបនីយកម្ម ក៏នាំឲ្យមានបញ្ហាប្រឈមផ្នែកបរិស្ថានថ្មីៗផងដែរ និងទម្រង់សង្គមថ្មីខុសពីមុន។ ចំណែកផលវិជ្ជមានវិញ គឺជួយលើកស្ទួយដល់កំណើនសេដ្ឋកិច្ច និងការច្នៃប្រឌិតថ្មី ក៏ដូចជាការកាត់បន្ថយភាពក្រីក្រផងដែរ។
- ឧស្សាហូបនីយកម្មកំពុងមានការវិវត្ត ទាំងនៅក្នុងតំបន់ជនបទផងដែរដែលនាំឲ្យមាន (ការប្រកួតប្រជែង) តម្រូវការដី ដែលទាំងនេះអាចបណ្តាលឲ្យមានការប្តូរទីតាំងរបស់ប្រជាពលរដ្ឋ ដែលជាហេតុបង្កឲ្យមានតំបន់លំនៅឋានថ្មី និងតម្រូវការសម្រាប់ហេដ្ឋារចនាសម្ព័ន្ធ។
- ការប្រែប្រួលអាកាសធាតុបន្តិចម្តងៗ ជាទូទៅអាចមើលឃើញតាមរយៈការប្រែប្រួលវដ្តទឹក ដែលធ្វើឲ្យមានការប្រែប្រួលដល់ការងារកសិកម្មដែលប្រជាពលរដ្ឋធ្លាប់ធ្វើ និងកើនឡើងនូវហានិភ័យគ្រោះធម្មជាតិទាំងនៅក្នុងតំបន់ជនបទ និងទីប្រជុំជន (ទឹកជំនន់ គ្រោះរាំងស្ងួត ខ្យល់ព្យុះ។ល។) ជាមួយនឹងការប្រែប្រួលទាំងនេះ ក៏កំពុងបង្កើតឲ្យមានភាពងាយរងគ្រោះថ្មីៗផងដែរ។

ទោះបីជាយ៉ាងណាក៏ដោយ ប្រទេសកម្ពុជាស្ថិតនៅតំបន់មានការវិវត្តខ្លាំងដែលអាចមើលឃើញតាមរយៈស្ថេរភាពនៃការអភិវឌ្ឍសេដ្ឋកិច្ចអស់រយៈពេល ១៥ ឆ្នាំកន្លងមកនេះ។ ការវិនិយោគជាតិ និងអន្តរជាតិ ការអភិវឌ្ឍសេដ្ឋកិច្ចថ្មីៗ និងក្នុងតំបន់ កំពុងតែមានការកើនឡើងយ៉ាងខ្លាំង។ កសិកម្មចម្រុះក៏ផ្តល់នូវទិសដៅថ្មីសម្រាប់ការអភិវឌ្ឍផងដែរ។ ដំណើរការវិមជ្ឈការ និងវិសហមជ្ឈការ ក៏បាននាំយកមកនូវមុខងារ និងការទទួលខុសត្រូវផ្នែករដ្ឋបាល និងនយោបាយទៅដល់ថ្នាក់ក្រោមជាតិ ហើយដំណើរការការងារនេះ ក៏បានបង្កើននូវកញ្ចប់ថវិកាសម្រាប់ធ្វើការងារអភិវឌ្ឍ និងហេដ្ឋារចនាសម្ព័ន្ធ។ ឱកាសនៃការអភិវឌ្ឍ គឺពិតជាមានជាក់ស្តែង ហើយត្រូវធ្វើការចាប់យកឱកាសដែលផ្តល់ផលប្រយោជន៍ដល់ប្រជាពលរដ្ឋទាំងអស់គ្នា។

# ៣. ក្របខ័ណ្ឌផែនការរៀបចំដែនដីថ្នាក់ក្រោមជាតិក្នុងប្រទេសកម្ពុជា

## ៣.១ ក្របខ័ណ្ឌគោលនយោបាយ និងច្បាប់

ក្របខ័ណ្ឌគោលនយោបាយ និងច្បាប់ដែលមាន ដែលត្រូវបានប្រើប្រាស់ជាឯកសារយោងសម្រាប់អន្តរវិស័យក្នុងការកសាងផែនការរៀបចំដែនដីមានពីរសំខាន់ៗ៖ កំណែទម្រង់ដីធ្លី និងកំណែទម្រង់ការអភិវឌ្ឍតាមបែបលទ្ធិប្រជាធិបតេយ្យ។

### ៣.១.១ កំណែទម្រង់ដីធ្លី

តាំងពីឆ្នាំ២០១៥ គោលនយោបាយដីធ្លី ឬ សៀវភៅ ស ដីធ្លី (ក្រុមប្រឹក្សាគោលនយោបាយដីធ្លី ២០១៥) គឺជាឯកសារគោលនយោបាយដ៏សំខាន់នៅក្នុងវិស័យនេះ។ ជាផ្នែកនៃអនុវិស័យគ្រប់គ្រងដីធ្លី គោលនយោបាយដីធ្លី ធ្វើការប្រមើលមើលដោយផ្អែកទៅលើមូលដ្ឋានច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាល រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងច្បាប់ស្តីអំពីការគ្រប់គ្រងរដ្ឋបាលឃុំសង្កាត់ថា អាជ្ញាធរមានសមត្ថកិច្ចត្រូវធ្វើការផ្តួចផ្តើម រៀបចំ សម្របសម្រួល និងអនុម័តលើផែនការរៀបចំដែនដីដែលមានបួនកម្រិតផ្សេងគ្នា៖ ថ្នាក់ជាតិ/តាមតំបន់ រាជធានី/ខេត្ត ក្រុង/ស្រុក/ខណ្ឌ និងថ្នាក់ឃុំ/សង្កាត់។

គោលនយោបាយជាតិស្តីអំពីផែនការរៀបចំដែនដីនៃប្រទេសកម្ពុជា ដែលអនុម័តដោយគណៈរដ្ឋមន្ត្រីនាថ្ងៃទី០៨ ខែមេសា ឆ្នាំ២០១១ គឺជាឯកសារដ៏សំខាន់ដែលគាំទ្រដល់ប្រព័ន្ធកសាងផែនការរៀបចំដែនដីថ្នាក់ក្រោមជាតិ (រាជរដ្ឋាភិបាលកម្ពុជា ២០១១)។ វាផ្តល់នូវចក្ខុវិស័យ គោលដៅ និងគោលបំណងយុទ្ធសាស្ត្រច្បាស់លាស់ សម្រាប់ការកសាងផែនការរៀបចំដែនដីនៅក្នុងប្រទេសកម្ពុជាដូចជា៖

- ការអភិវឌ្ឍដែនដីនៅក្នុងព្រះរាជាណាចក្រកម្ពុជា
- ការកំណត់តំបន់សមស្រួល តំបន់អាទិភាពសម្រាប់ការស្នាក់នៅ ប៉ូលអភិវឌ្ឍន៍ និងអ័ក្សនៃការអភិវឌ្ឍ
- ការកសាងផែនការគ្រប់គ្រងការអភិវឌ្ឍសេដ្ឋកិច្ច និងឱកាសការងារ
- ការកសាងផែនការរៀបចំហេដ្ឋារចនាសម្ព័ន្ធសង្គម និងវប្បធម៌
- ការកសាងផែនការ និងការគ្រប់គ្រងធម្មជាតិដែលទ្រទ្រង់ដល់ជីវភាពរស់នៅ
- ការកសាងផែនការគ្រប់គ្រងដីព្រៃឈើ ដីកសិកម្ម ជលផល ឧស្សាហកម្ម រ៉ែ ថាមពល និងតំបន់អភិរក្ស
- ការកសាងផែនការហេដ្ឋារចនាសម្ព័ន្ធបច្ចេកទេស និងសេវាកម្ម

វាក៏បង្ហាញជាក់លាក់ពីយន្តការ ការរៀបចំ និងឋានានុក្រមនៃផែនការរៀបចំដែនដីពីថ្នាក់ជាតិទៅដល់ថ្នាក់ក្រោមជាតិ។

កន្លងមកច្បាប់ឆ្នាំ១៩៩៤ ស្តីពីការរៀបចំទឹកដី នគរូបនីយកម្ម និងសំណង់ គឺជាឯកសារផ្លូវច្បាប់ដ៏សំខាន់បំផុតសម្រាប់ការកសាងផែនការរៀបចំដែនដី (រាជរដ្ឋាភិបាលកម្ពុជា ១៩៩៤)។ វាបើកផ្លូវដល់ខេត្ត ក្រុង ទីប្រជុំជន ក្នុងការធ្វើការរៀបចំប្លង់គោលអភិវឌ្ឍន៍របស់ខ្លួនសម្រាប់ការចាត់ចែងរៀបចំឡើងវិញ និងការអភិវឌ្ឍដែនដីរបស់ខ្លួន។ បច្ចុប្បន្ននេះ ច្បាប់នេះកំពុងស្ថិតនៅក្នុងការកែសម្រួលឡើងវិញ ហើយនឹងផ្តល់ជាមូលដ្ឋានផ្លូវច្បាប់យ៉ាងលម្អិតសម្រាប់ការរៀបចំគ្រប់គ្រងដែនដី និងការធ្វើផែនការទីប្រជុំជននាពេលអនាគត។ ចំពោះថាតើការការពារ ការអនុវត្ត ឧបករណ៍ និងការលើកទឹកចិត្តក្នុងការកសាងផែនការរៀបចំដែនដី នឹងត្រូវបញ្ចូលក្នុងច្បាប់នេះ ឬក៏នឹងត្រូវបង្កើតឡើងដើម្បីអមជាមួយច្បាប់នេះក្នុងកម្រិតណានោះ គឺនៅមិនទាន់ដឹងនៅឡើយនោះទេ។

ច្បាប់ឆ្នាំ១៩៩៤ ស្តីពីការរៀបចំទឹកដី នគរូបនីយកម្ម និងសំណង់ ត្រូវបានប្រតិបត្តិ និងបំពេញបន្ថែមដោយអនុក្រឹត្យលេខ៤២ អនក្រ.បក (រាជារដ្ឋាភិបាលកម្ពុជា ឆ្នាំ២០១៥) ស្តីពីនគរូបនីយកម្ម រាជធានី ក្រុង និងទីប្រជុំជន ដែលប្រកាសឲ្យប្រើនាថ្ងៃទី០៣ ខែមេសា ឆ្នាំ២០១៥។ អនុក្រឹត្យនេះ បានកំណត់ពីទំហំ មាតិកា និងដំណើរការក្នុងការកសាងផែនការរូបវន្តបីផ្សេងគ្នា៖ ប្លង់គោល/ប្លង់គោលប្រើប្រាស់ដី ផែនការប្រើប្រាស់ដី និងប្លង់លម្អិតនគរូបនីយកម្ម។ វាធ្វើការញែកដាច់ពីគ្នារវាងតំបន់ដែលអាចសាងសង់បានដែលជាតំបន់ដែលអនុញ្ញាតដល់ការសាងសង់ និងតំបន់កម្រិតការសាងសង់ដែលសំដៅដល់តំបន់ដែលត្រូវអនុញ្ញាតឲ្យសាងសង់តែក្នុងលក្ខខណ្ឌពិសេសតែប៉ុណ្ណោះនៅក្នុងតំបន់កសិកម្ម។

ព្រះរាជក្រឹត្យលេខ នស/រកត/០៥១២/៤៦៣ បានបង្កើតគណៈកម្មាធិការរៀបចំដែនដី និងនគរូបនីយកម្មថ្នាក់ជាតិ (គ.ដ.ន.ជ) ដែលជាគណៈកម្មាធិការអន្តរក្រសួងយ៉ាងសំខាន់ដើម្បីធ្វើការណែនាំតម្រង់ទិសដល់ការកសាងផែនការរៀបចំដែនដីនៅក្នុងប្រទេសកម្ពុជា (រាជរដ្ឋាភិបាលកម្ពុជា ២០១២a)។ ព្រះរាជក្រឹត្យនេះ ត្រូវបានបំពេញបន្ថែមដោយអនុក្រឹត្យលេខ ១០៨ ដែលធ្វើការកំណត់អាណត្តិរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ (ក្រសួង ដនស) ជាលេខាធិការរបស់ គ.ដ.ន.ជ។ អនុក្រឹត្យលេខ៧៧ ស្តីពីការបង្កើតគណៈកម្មាធិការរៀបចំដែនដី និងនគរូបនីយកម្មថ្នាក់រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ត្រូវបានបង្កើតឡើងក្នុងឆ្នាំ២០១២ សម្រាប់ការការរៀបចំដែនដី និងនគរូបនីយកម្ម (រាជរដ្ឋាភិបាលកម្ពុជា ២០១២b)។ អនុក្រឹត្យនេះបានបើកផ្លូវដល់ការរៀបចំ ការទទួលខុសត្រូវចំពោះការកសាងផែនការរៀបចំដែនដីថ្នាក់ក្រោមជាតិ។ គ.ដ.ន.ជ បានបង្កើតដំណើការកសាងផែនការតាមកម្រិតនីមួយៗដែលចេញសេចក្តីសម្រេចដោយគណៈកម្មាធិការនេះ។ សៀវភៅណែនាំជាស៊េរីនេះ បំពេញបន្ថែមទៅលើដំណើការកសាងផែនការដែលបានបង្កើតឡើងដោយ គ.ដ.ន.ជ ដោយនាំយកមកនូវបទពិសោធន៍ បច្ចេកទេស និងការអនុវត្តជាក់ស្តែង ដោយផ្តោតសំខាន់ទៅលើការជួយឲ្យអ្នកធ្វើផែនការរៀបចំដែនដីធ្វើការអនុវត្តការងារទៅតាមដំណើរការបាន។

### ៣.១.២ កំណែទម្រង់ការអភិវឌ្ឍតាមបែបលទ្ធិប្រជាធិបតេយ្យ (វិមជ្ឈការ និងវិសហមជ្ឈការ)

កំណែទម្រង់ការអភិវឌ្ឍតាមបែបលទ្ធិប្រជាធិបតេយ្យ (វិមជ្ឈការ និងវិសហមជ្ឈការ) មានគោលបំណងជំនួសនូវប្រព័ន្ធ និងរចនាសម្ព័ន្ធគ្រប់គ្រងស្ថាប័នរដ្ឋ ដោយបង្កើតនូវប្រព័ន្ធគ្រប់គ្រងថ្មីដែលផ្អែកទៅលើគោលការណ៍លទ្ធិប្រជាធិបតេយ្យ ការចូលរួមរបស់ប្រជាពលរដ្ឋ ការទទួលខុសត្រូវ និងប្រសិទ្ធភាព (រាជរដ្ឋាភិបាលកម្ពុជា ២០០៥)។

ខ្លឹមសារសំខាន់ក្នុងកំណែទម្រង់នេះគឺដើម្បីបង្កើតនូវរដ្ឋបាលឯកភាពថ្នាក់ខេត្ត និងស្រុក/ខណ្ឌ/ក្រុង ហើយផ្តល់អំណាចដល់រដ្ឋបាលឯកភាពទាំងនេះក្នុងការរៀបចំ អនុម័ត និងអនុវត្តផែនការរួម និងថវិកា គ្រប់គ្រងបុគ្គលិក និងសម្របសម្រួលការអភិវឌ្ឍ និងផ្តល់សេវាសាធារណៈក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។ ពាក្យថា " ឯកភាព " សំដៅដល់គោលនយោបាយ ផែនការការងារ និងថវិកាមកពីក្រសួងនឹងត្រូវធ្វើសមាហរណកម្មទៅក្នុងផែនការអភិវឌ្ឍន៍រយៈពេល៥ឆ្នាំរួម កម្មវិធីវិនិយោគរំកិល៣ឆ្នាំ និងផែនការថវិកាប្រចាំឆ្នាំ។

តួនាទីរបស់រដ្ឋបាលថ្នាក់ក្រោមជាតិផ្សេងៗគ្នា បច្ចុប្បន្ននេះត្រូវបានចែងយ៉ាងច្បាស់នៅក្នុងច្បាប់ស្តីអំពីការគ្រប់គ្រងរដ្ឋបាល រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ។ វាបានធ្វើការញែកចេញពីគ្នារវាងក្រុមប្រឹក្សាថ្នាក់ក្រោមជាតិ គណៈអភិបាល និងចំនួនគណៈកម្មាធិការដែលត្រូវកំណត់ដោយក្រុមប្រឹក្សា ដើម្បីគាំទ្រដល់ការងាររដ្ឋបាលជាក់លាក់ (រដ្ឋាភិបាលកម្ពុជា ២០០៨a)។

ក្រុមប្រឹក្សា មានសិទ្ធិអំណាចក្នុងការធ្វើសេចក្តីសម្រេចចិត្តខាងបញ្ញត្តិ និងខាងប្រតិបត្តិ។ ក្រុមប្រឹក្សាគួរប្រើប្រាស់សិទ្ធិអំណាចបញ្ញត្តិរបស់ខ្លួនតាមរយៈការចេញដីការ និងមានគណនេយ្យភាពដោយផ្ទាល់ចំពោះប្រជាពលរដ្ឋទាំងអស់ ដើម្បីធ្វើការសម្រេចចិត្ត និងធានាដល់ការអភិវឌ្ឍតាមបែបលទ្ធិប្រជាធិបតេយ្យក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។ គណៈអភិបាលតំណាងឲ្យក្រសួង និងស្ថាប័នរបស់រដ្ឋាភិបាល ក្នុងការគ្រប់គ្រង សម្របសម្រួល និងតម្រង់ទិសដល់មន្ទីរ និងអង្គភាពជំនាញទាំងអស់របស់ក្រសួង និងស្ថាប័នរដ្ឋដែលបំពេញការងារក្នុងដែនសមត្ថកិច្ចរបស់ក្រុមប្រឹក្សា។ អភិបាលត្រូវមានគណនេយ្យភាពចំពោះរាជរដ្ឋាភិបាល ស្ថាប័ន និងក្រសួងរបស់រដ្ឋ។

ក្រុមប្រឹក្សាត្រូវរៀបចំបង្កើតគណៈកម្មាធិការមួយចំនួនដែលមានតួនាទីជាក់លាក់ផ្សេងៗគ្នា។ គណៈកម្មាធិការសម្របសម្រួលបច្ចេកទេស ត្រូវខិតខំធានាឲ្យបានថាផែនការអភិវឌ្ឍន៍ និងថវិការបស់ក្រសួង ស្ថាប័ន ឬមន្ទីរ អង្គភាពនានារបស់រដ្ឋាភិបាលដែលផ្តល់សេវា សម្ភារៈ ឬហេដ្ឋារចនាសម្ព័ន្ធដោយផ្ទាល់នៅក្នុងដែនសមត្ថកិច្ចរបស់ក្រុមប្រឹក្សា ត្រូវបានបញ្ចូលយ៉ាងត្រឹមត្រូវទៅក្នុងផែនការអភិវឌ្ឍន៍រយៈពេលប្រាំ (០៥) ឆ្នាំ កម្មវិធីវិនិយោគបី (០៣) ឆ្នាំរំកិលប្រចាំឆ្នាំ ក្របខ័ណ្ឌចំណាយរយៈពេលមធ្យម និងផែនការថវិកាប្រចាំឆ្នាំរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ។

## ៣.២ ក្របខ័ណ្ឌផែនការ

រាជរដ្ឋាភិបាលកម្ពុជា បានបង្កើតក្របខ័ណ្ឌផែនការដែលបានរៀបចំពីការទទួលខុសត្រូវ និងតួនាទីក្នុងការកសាងផែនការតាមជំនាញទៅតាមកម្រិតរដ្ឋបាលផ្សេងៗគ្នា (មើលតារាង១)។ ផែនការរៀបចំដែនដី ជាផែនការដ៏ចាំបាច់មួយនៅក្នុងក្របខ័ណ្ឌផែនការទាំងមូល។

### ផែនការយុទ្ធសាស្ត្រអភិវឌ្ឍជាតិ

នៅថ្នាក់ជាតិ រាជរដ្ឋាភិបាលកម្ពុជា បង្កើតនូវផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ថ្នាក់ជាតិដែលជាឯកសារផែនការយុទ្ធសាស្ត្រដែលបម្រើជាផែនទីបង្ហាញផ្លូវសម្រាប់ការអភិវឌ្ឍប្រទេស (រាជរដ្ឋាភិបាលកម្ពុជា ២០១០)។ ផែនការនេះ ត្រូវបានប្រើប្រាស់ដើម្បីជួយរៀបចំដល់កម្មវិធីវិនិយោគសាធារណៈប្រចាំឆ្នាំ។ ក្រសួងផែនការ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ ធ្វើការសម្របសម្រួលដល់ការអនុវត្តផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ តាមរយៈក្រុមការងារបច្ចេកទេសនានាជាមួយនឹងការចូលរួមពីតំណាងសហគមន៍ម្ចាស់ជំនួយ។

### ផែនការតាមវិស័យ

ដោយផ្អែកលើផែនការយុទ្ធសាស្ត្រអភិវឌ្ឍជាតិ ក្រសួងនីមួយៗ រៀបចំបង្កើតផែនការជាក់លាក់ និងយុទ្ធសាស្ត្រតាមវិស័យរួមជាមួយនឹងការទទួលខុសត្រូវជាមួយមន្ទីរខេត្ត និងការិយាល័យក្រុង/ស្រុក ។ ផែនការ និងគោលនយោបាយតាមវិស័យទាំងនេះ គឺជាមាគ៌ាណែនាំដល់ការងាររបស់ស្ថាប័នជំនាញរបស់រដ្ឋាភិបាលថ្នាក់ក្រោមជាតិ។ ទោះបីជាយ៉ាងណាក៏ដោយ គោលនយោបាយសំខាន់ៗ និងប្រព័ន្ធផែនការខ្សែបណ្តោយដ៏ច្បាស់លាស់មួយ មានភាគច្រើននៅក្នុងក្រសួងដែលទទួលជំនួយរយៈពេលវែង (Horng and Craig 2008)។

### ផែនការរដ្ឋបាលឯកភាពថ្នាក់ក្រោមជាតិ

នៅថ្នាក់ក្រោមជាតិ "កំណែទម្រង់ការអភិវឌ្ឍតាមបែបលទ្ធិប្រជាធិបតេយ្យ (វិមជ្ឈការ និងវិសហមជ្ឈការ)" បានធ្វើការកែប្រែគួរឲ្យកត់សំគាល់ទៅលើប្រព័ន្ធផែនការដែលមានមុនពេលប្រកាសឲ្យប្រើប្រាស់ច្បាប់ស្តីអំពីការគ្រប់គ្រងរដ្ឋបាល រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ក្នុងខែឧសភា ឆ្នាំ ២០០៨ (រាជរដ្ឋាភិបាលកម្ពុជា ២០០៨a)។

រដ្ឋបាលឯកភាពថ្នាក់ក្រោមជាតិនីមួយៗមានអាណត្តិ (តួនាទី) បង្កើតផែនការអភិវឌ្ឍន៍រយៈពេលប្រាំ (០៥) ឆ្នាំ និងកម្មវិធីវិនិយោគបី (០៣) ឆ្នាំរំកិល រួមមាន៖

- ចក្ខុវិស័យ គោលដៅ និងគោលបំណងសម្រាប់ការអភិវឌ្ឍក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។

- ការប៉ាន់ប្រមាណពីកម្រិតនៃស្ថានភាពអភិវឌ្ឍន៍ដែលមានស្រាប់ក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។
- ការប៉ាន់ប្រមាណពីតម្រូវការអភិវឌ្ឍន៍អាទិភាព (សេវា បរិក្ខា ហេដ្ឋារចនាសម្ព័ន្ធសាធារណៈ ការកាត់បន្ថយភាពក្រីក្រ និងតម្រូវការរបស់បុរសស្ត្រី យុវជន កុមារ និងក្រុមដែលងាយរងគ្រោះ)។
- បង្កើតក្របខ័ណ្ឌអភិវឌ្ឍន៍ដែលមានចែងអំពីគោលការណ៍សម្រាប់ការប្រើប្រាស់និងគ្រប់គ្រងដីធ្លី និងធនធានធម្មជាតិ។
- ផែនការគ្រប់គ្រងគ្រោះមហន្តរាយ។
- ផែនការហិរញ្ញវត្ថុ ដោយត្រូវរាប់បញ្ចូលទាំងកម្មវិធីវិនិយោគបី(០៣)ឆ្នាំរំកិល បច្ចុប្បន្នភាពគ្រោងថវិកាសម្រាប់រយៈពេល១២ខែ និងផែនការអភិវឌ្ឍន៍មូលធន។
- យុទ្ធសាស្ត្រសម្រាប់ការអនុវត្តដោយរួមបញ្ចូលទាំងសុចនាករអនុវត្តសំខាន់ៗ។

**តារាង១៖** ប្រព័ន្ធផែនការ និងឋានានុក្រមរដ្ឋបាលប្រទេសកម្ពុជា

| កម្រិត | | ផែនការអភិវឌ្ឍ | ផែនការហិរញ្ញវត្ថុ និងការវិនិយោគ | ផែនការតាមវិស័យ |
|---|---|---|---|---|
| ថ្នាក់ជាតិ | | • ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិរយៈពេល៥ឆ្នាំ<br>• យុទ្ធសាស្ត្រកាត់បន្ថយភាពក្រីក្រ<br>• គោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍ | • កម្មវិធីវិនិយោគសាធារណៈ | • ផែនការតាមវិស័យពីក្រសួងជំនាញ |
| ថ្នាក់ក្រោមជាតិ | រាជធានី | • ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ រយៈពេលប្រាំ (០៥) ឆ្នាំ | • កម្មវិធីវិនិយោគបី (០៣) ឆ្នាំរំកិល<br>• ផែនការហិរញ្ញវត្ថុប្រចាំឆ្នាំ | • ផែនការតាមវិស័យពីក្រសួងជំនាញ |
| | ខេត្ត | | | |
| | ក្រុង ស្រុក និងខណ្ឌ | | • កម្មវិធីវិនិយោគបី (០៣) ឆ្នាំរំកិល<br>• ផែនការហិរញ្ញវត្ថុប្រចាំឆ្នាំ | • ផែនការតាមវិស័យពីក្រសួងជំនាញ |
| មូលដ្ឋាន | សង្កាត់និងឃុំ | • ផែនការអភិវឌ្ឍន៍ឃុំ/សង្កាត់រយៈពេល៥ឆ្នាំ | • កម្មវិធីវិនិយោគឃុំ/សង្កាត់ ៣ ឆ្នាំរំកិល | • ផែនការតាមវិស័យពីក្រសួងជំនាញ |
| | ភូមិ | • ផែនការអភិវឌ្ឍមូលដ្ឋាន | | |

## ៣.៣ ប្រព័ន្ធផែនការរៀបចំដែនដី

គោលនយោបាយថ្នាក់ជាតិស្តីអំពីផែនការរៀបចំដែនដី បានកំណត់ជាក់លាក់ពីឋានានុក្រមផែនការរៀបចំដែនដីនៅក្នុងព្រះរាជាណាចក្រកម្ពុជា។ វាបានធ្វើចំណាត់ថ្នាក់ផែនការរៀបចំដែនដីទៅតាមកម្រិតរដ្ឋបាលផ្សេងៗគ្នា កំណត់ពីទំហំការងារទាំងមូលរបស់ផែនការនីមួយៗនិងកំណត់ពីយន្តការសម្រាប់ការរៀបចំ និងការអនុម័តទៅលើផែនការ (រាជរដ្ឋាភិបាលកម្ពុជា ២០១១) (រូបភាព១)។

**ផែនការរៀបចំដែនដីថ្នាក់ខេត្ត តាមតំបន់ និងថ្នាក់ជាតិ** សំដៅដល់ផែនការដែលមានចក្ខុវិស័យ និងការតម្រង់ទិសជាយុទ្ធសាស្ត្រនៃផែនការការប្រើប្រាស់ដី និងការអភិវឌ្ឍផ្នែករូបវន្តដោយផ្អែកទៅលើសក្តានុពលភូមិសាស្ត្ររបស់តំបន់នីមួយៗនៅក្នុងដែនដីរបស់ជាតិ តំបន់ និងរបស់ខេត្តរៀងៗខ្លួន។

**ប្លង់គោលប្រើប្រាស់ដីរាជធានី ក្រុង ខណ្ឌ និងស្រុក** ( នៅក្នុងថ្នាក់ក្រុង ជាទូទៅហៅថា "ប្លង់គោល" ) សំដៅដល់ផែនការដែលមានចក្ខុវិស័យនិងយុទ្ធសាស្ត្ររួមសម្រាប់ការអភិវឌ្ឍផ្នែករូបវន្តនិងការកំណត់តំបន់ ជាមួយនឹងបណ្តាញផ្លូវ និងហេដ្ឋារចនាសម្ព័ន្ធសំខាន់ៗដែលបានកំណត់យ៉ាងត្រឹមត្រូវ និងការធ្វើសមាហរណកម្មក្របខ័ណ្ឌនៃការកសាងផែនការថ្នាក់រាជធានី ក្រុង ខណ្ឌ និងស្រុក ទៅក្នុងផែនការរៀបចំដែនដីថ្នាក់ជាតិនិងថ្នាក់តំបន់។

**ផែនការប្រើប្រាស់ដីឃុំ/សង្កាត់** សំដៅដល់ការកសាងផែនការប្រើប្រាស់ដីសម្រាប់ឃុំ/សង្កាត់ ទាំងដីកម្មសិទ្ធិឯកជន និងដីរដ្ឋ ដោយគិតគូរពិចារណាទៅលើសក្តានុពលដី និងធនធានទឹក លទ្ធភាពក្នុងការប្រើប្រាស់ដី លក្ខណៈសម្បត្តិសេដ្ឋកិច្ចនិងសង្គម ដើម្បីធ្វើការចាត់ចែងប្រើប្រាស់ដីឲ្យបានសមរម្យ។




**រូបភាព១៖** ឋានានុក្រមផែនការរៀបចំដែនដីនៅក្នុងប្រទេសកម្ពុជា

## ៤. ទំហំ និងខ្លឹមសាររបស់ផែនការរៀបចំដែនដីថ្នាក់ក្រោមជាតិ

ទោះបីជាផែនការរៀបចំដែនដីថ្នាក់ក្រោមជាតិទាំងអស់ មានដំណើរការប្រហាក់ប្រហែលគ្នា ព្រមទាំងមានគោលការណ៍ដូចគ្នាក៏ដោយ ក៏វាមានលក្ខណៈខុសប្លែកគ្នាមួយចំនួនលើផ្នែកទំហំមាត្រដ្ឋាន វិសាលភាព យុទ្ធសាស្ត្រដែលបានបង្កើតឡើង ក៏ដូចជាការអនុវត្តផងដែរ។ វាមានសារៈសំខាន់ណាស់ក្នុងការធានាឲ្យបានថាផែនការរៀបចំដែនដីក្នុងកម្រិតផ្សេងៗគ្នាពីថ្នាក់ខេត្តទៅថ្នាក់ឃុំបង្កើតបានជាក្របខ័ណ្ឌផែនការរៀបចំដែនដីមួយដែលមានសមាហរណកម្មយ៉ាងស្អិតរមួតជាមួយគ្នា។ យុទ្ធសាស្ត្រដែលបានកំណត់ហើយ គួរត្រូវធ្វើឡើងឲ្យបានច្បាស់លាស់ និងបំពេញឲ្យគ្នាទៅវិញទៅមក ដោយមិនបង្កើតឡើងតាមគ្នាដដែលៗ និងត្រួតស៊ីគ្នានោះទេ។ មានន័យថា ផែនការថ្នាក់ក្រោម (កម្រិតទាប) ត្រូវអនុវត្តឲ្យស្របទៅតាមផែនការថ្នាក់លើ (កម្រិតខ្ពស់) ហើយផែនការកម្រិតខ្ពស់ត្រូវចូលរួមចំណែកបំពេញបន្ថែមដល់ផែនការកម្រិតទាប។

នៅក្នុងក្របខ័ណ្ឌផែនការរៀបចំដែនដីថ្នាក់ខេត្តដែលបានធ្វើសមាហរណកម្មនេះ គោល-នយោបាយថ្នាក់ជាតិ ផ្តល់និងបញ្ជ្រាបទៅថ្នាក់ក្រោមតាមរយៈការកសាងផែនការនូវកម្រិតផ្សេងៗគ្នាតាមរយៈជំហាននេះ វាចូលរួមចំណែកដល់ការអនុវត្តគោលនយោបាយទាំងនេះ ព្រមទាំងពន្យល់លម្អិតបន្ថែមគោលនយោបាយនេះតាមរយៈការឆ្លុះបញ្ចាំងពីស្ថានភាពក្នុងមូលដ្ឋាន។ ផ្ទុយមកវិញ ទិដ្ឋភាពជាក់ស្តែងនៅថ្នាក់មូលដ្ឋានផ្តល់នូវបច្ចុប្បន្នភាពរបស់ផែនការកម្រិតខ្ពស់ដោយវាផ្តល់នូវព័ត៌មានដីធ្លីដែលបានផ្ទៀងផ្ទាត់នៅមូលដ្ឋានជាក់ស្តែង តម្រូវការ និងសក្តានុពល។ ក្របខ័ណ្ឌផែនការសមាហរណកម្មនេះ ក៏ផ្តល់បន្ថែមទៀតនូវស្ថេរភាពនិងគុណភាពកំឡុងពេលធ្វើបច្ចុប្បន្នភាពផែនការ។ ជារួម វាផ្តល់នូវលទ្ធផលតាមសេចក្តីប្រាថ្នាតាមរយៈដំណើរការកសាងផែនការកម្រិតផ្សេងៗគ្នានៅក្នុងខេត្ត។ នេះជាអ្វីដែលគោលនយោបាយជាតិស្តីអំពីផែនការរៀបចំដែនដីចាត់ទុកជាដំណើរការទ្វេទិស (ពីក្រោមឡើងលើ/ពីលើចុះក្រោម) សម្រាប់ការធ្វើសេចក្តីសម្រេចចិត្ត (រាជរដ្ឋាភិបាលកម្ពុជា ២០១១)។

### ៤.១ ផែនការរៀបចំដែនដីថ្នាក់ខេត្ត

| | |
|---|---|
| ប្រភេទផែនការ | ផែនការរៀបចំដែនដីថ្នាក់ខេត្ត ជាក្របខ័ណ្ឌអភិវឌ្ឍន៍ដែនដីដោយផ្អែកទៅលើចក្ខុវិស័យ។ វាផ្តល់នូវការតម្រង់ទិសជាយុទ្ធសាស្ត្រសម្រាប់ការអភិវឌ្ឍដែនដីរបស់ខេត្ត។ |

- ចក្ខុវិស័យបង្ហាញពីការអភិវឌ្ឍដែនដីតាមសេចក្តីប្រាថ្នាសម្រាប់រយៈពេលវែង។

- យុទ្ធសាស្ត្រត្រូវបានផ្សារភ្ជាប់ទៅនឹងការអភិវឌ្ឍដែនដីតាមសេចក្តីប្រាថ្នា ដោយភ្ជាប់ជាមួយនឹងវិធីសាស្ត្រ ឬមធ្យោបាយផ្សេងៗក្នុងការធ្វើឲ្យសម្រេចបាននូវចក្ខុវិស័យ។

តួនាទី និងទំហំ

ផែនការរៀបចំដែនដីថ្នាក់ខេត្ត បានបង្កើតទំនាក់ទំនងរវាងគោលនយោបាយដែលពាក់ព័ន្ធដែនដីថ្នាក់ជាតិ កម្មវិធី ផែនការ និងយុទ្ធសាស្ត្រ ជាមួយនឹងការកសាងផែនការរៀបចំដែនដីថ្នាក់មូលដ្ឋាន។ ម្យ៉ាងវិញទៀត វាធ្វើការសម្របសម្រួល និងធ្វើសមាហរណកម្មគោលនយោបាយ កម្មវិធី ផែនការ និងយុទ្ធសាស្ត្រតាមវិស័យក្នុងគោលបំណងកសាងផែនការរៀបចំដែនដីផ្ទាល់។

ផែនការនេះ ក៏បង្ហាញពីផែនការអភិវឌ្ឍន៍ខេត្តពាក់កណ្តាលអាណត្តិ (ស្ថិតនៅក្រោមគណៈកម្មាធិការជាតិ សម្រាប់ការអភិវឌ្ឍតាមបែបលទ្ធិប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ) និងផ្តល់នូវការតម្រង់ទិសដល់ការកសាងផែនការរៀបចំដែនដីថ្នាក់ក្រោមៗសម្រាប់ថ្នាក់ក្រុង និងស្រុក។

ផែនការរៀបចំដែនដីថ្នាក់ខេត្ត មានគោលបំណងកំណត់នូវទម្រង់រចនាសម្ព័ន្ធដែនដីខេត្តនាពេលអនាគតតាមក្តីប្រាថ្នា និងធ្វើការរៀបចំនូវមុខងារដែលធ្វើការឆ្លើយតបទៅនឹងតំបន់ផ្សេងៗគ្នាក្នុងដែនដីរបស់ខេត្ត។ ដូច្នេះ៖

- វាធ្វើការពិនិត្យ និងគិតគូរដល់លក្ខណៈសម្បត្តិរបស់ខេត្តនៅក្នុងតំបន់។
- វាកំណត់និងវិភាគទម្រង់លក្ខណៈដែនដីដែលមានស្រាប់ និងទម្រង់នៃការអភិវឌ្ឍដែនដី។
- វាបង្កើតនូវទម្រង់លក្ខណៈដែនដីនៃការតាំងទីលំនៅ និងហេដ្ឋារចនាសម្ព័ន្ធរបស់ដែនដីតាមតំបន់លំហ និងតំបន់ដែលមានមុខងារពិសេស ក៏ដូចជាទំនាក់ទំនងរបស់សមាសភាគទាំងនេះ ដោយផ្អែកទៅលើសក្តានុពល និងតម្រូវការនៅមូលដ្ឋាន ហើយក៏ត្រូវស្របជាមួយនឹងការណែនាំតម្រង់ទិសពីថ្នាក់ជាតិផងដែរ (គោលនយោបាយ កម្មវិធី ផែនការ និងយុទ្ធសាស្ត្រ)។
- វាកំណត់មុខងារសម្រាប់តំបន់ជនបទ និងទីប្រជុំជនផ្សេងៗគ្នា និងបង្កើតនូវវិធានការផ្សេងៗដែលឆ្លើយតបទៅនឹងមុខងារទាំងនោះក្នុងការលើកស្ទួយដល់ការអភិវឌ្ឍប្រកបដោយចីរភាព។

- វាផ្តល់នូវការតម្រង់ទិស ការណែនាំ និងដាក់កម្រិតដល់ការកសាងប្លង់គោលប្រើប្រាស់ដីថ្នាក់ក្រោមៗទៀតរបស់ថ្នាក់ស្រុក និងក្រុងនៅក្នុងខេត្ត។
- ហើយវាក៏ជាឯកសារយោងសម្រាប់ការកសាងផែនការអភិវឌ្ឍន៍រយៈពេលមធ្យម និងកម្មវិធីវិនិយោគរបស់ខេត្ត។

ខ្លឹមសារសំខាន់ៗរបស់ផែនការរៀបចំដែនដីថ្នាក់ខេត្តរួមមាន៖

- ការអភិវឌ្ឍដែលបានប្រមើលមើលទុកមុននៃទម្រង់លក្ខណៈការតាំងទីលំនៅសំខាន់ៗនៅក្នុងខេត្ត ដែលត្រូវបានបង្កើតឡើងដោយប្រភេទតំបន់តាំងទីលំនៅផ្សេងៗគ្នា (ចាប់ពីប្រភេទតំបន់តាំងទីលំនៅកម្រិតខ្ពស់ រហូតដល់កម្រិតទាប ដែលភ្ជាប់ទំនាក់ទំនងជាមួយនឹងតំបន់ជនបទដែលនៅជុំវិញនោះ) ដោយផ្តល់នូវហេដ្ឋារចនាសម្ព័ន្ធបច្ចេកទេស និងសង្គម និងគ្រឿងបរិក្ខារផ្សេងៗ និងធ្វើការភ្ជាប់មជ្ឈមណ្ឌល ឬប៉ូលអភិវឌ្ឍន៍ផ្សេងៗជាមួយគ្នាដោយច្រកផ្លូវអភិវឌ្ឍន៍។
- ទម្រង់លក្ខណៈតំបន់ទេសភាព និងតំបន់លំហាដែលបានប្រមើលមើលទុកមុន ជាពិសេសសម្រាប់ការផ្តល់ជាទីជំរក និងការការពារប្រព័ន្ធអេកូឡូស៊ី (ដូចជាព្រៃឈើ និង ទីជម្រាល) កសិកម្ម និងឧស្សាហកម្មទាញយកធនធានរ៉ែ ការកំណត់តំបន់សម្រាប់ការគ្រប់គ្រងទឹកជំនន់ តំបន់ទេសចរណ៍ និងតំបន់កំសាន្ត។
- ច្រកផ្លូវសម្រាប់តំបន់ទ្រនាប់សមស្រប និងទីតាំងសម្រាប់ការដឹកជញ្ជូន និងការផ្គត់ផ្គង់ហេដ្ឋារចនាសម្ព័ន្ធដែលធានាដល់ការធ្វើចរាចរណ៍ និងការចល័តរបស់ប្រជាពលរដ្ឋ និងទំនិញ ដែលជាសេចក្តីត្រូវការសម្រាប់ការអភិវឌ្ឍសេដ្ឋកិច្ច និងការទទួលបានហេដ្ឋារចនាសម្ព័ន្ធសង្គម ដោយជៀសវាង ឬកាត់បន្ថយដល់ការធ្វើឲ្យខូចខាតដល់ប្រព័ន្ធអេកូឡូស៊ី។
- តំបន់ដែលមានមុខងារពិសេស ឧទាហរណ៍ដូចជា៖ តំបន់សមស្របសម្រាប់សម្បទានដី សេដ្ឋកិច្ច ឬសង្គមកិច្ច តំបន់សេដ្ឋកិច្ចពិសេសជាដើម ដោយធានាដល់ការកាត់បន្ថយនូវផលប៉ះពាល់ទំនាស់លើការប្រើប្រាស់ដី (ឧ. តំបន់លំនៅឋាន និងតំបន់ការពារបរិស្ថាន)។
- វិធានការនានាដែលធានាដល់ការអភិវឌ្ឍដែនដីដែលបានប្រមើលមើលទុកជាមុន រួមមានការកំណត់អាទិភាព និងការកម្រិតដល់ការប្រើប្រាស់ និងមុខងារតំបន់ជាក់លាក់មួយចំនួន ឬការវាយតម្លៃទៅលើជម្រើសសម្រាប់ការអភិវឌ្ឍផ្សេងៗសម្រាប់តំបន់និងផ្លូវដែលមានផលប៉ះពាល់ផ្នែកសង្គម និងបរិស្ថាន។

ការទទួលខុសត្រូវផ្នែកស្ថាប័ន




**រូបភាព ២ ៖** រចនាសម្ព័ន្ធស្ថាប័ន និងអ្នកពាក់ព័ន្ធនៅក្នុងផែនការរៀបចំដែនដីថ្នាក់ខេត្ត

| | |
|---|---|
| រយៈពេល | ២០ ឆ្នាំ |
| មាត្រដ្ឋាន | ១/២៥០ ០០០ ទៅ ១/១០០ ០០០ |

ដំណើរការកសាង

ផែនការរួម — ដំណើរការក្នុងការរៀបចំកសាងផែនការរៀបចំដែនដីថ្នាក់ខេត្តមាន ៦ ជំហានសំខាន់ៗ ដែលនឹងត្រូវធ្វើឡើងក្នុងរយៈពេលប្រមាណជា ២ ឆ្នាំ (រូបភាព៣)។ នេះជារយៈពេលមួយដែលការងារនេះ ត្រូវបានធ្វើឡើងប្រកបដោយភាពរលូនគ្មានការរំខាន ដោយមានធនធាន និងសមត្ថភាពគ្រប់គ្រាន់។ ប្រសិនបើត្រូវធ្វើការកសាងសមត្ថភាព ដំណាលគ្នាក្នុងកំឡុងពេលដំណើរការកសាងផែនការនោះ រយៈពេលនៃការកសាងផែនការនេះនឹងត្រូវចំណាយពេលវែងជាងនេះ។

| ជំហាន | ការងារ | រយៈពេល |
|---|---|---|
| **ជំហានទី១ ការរៀបចំ និងការចាប់ផ្តើមដំណើរការកសាងផែនការរៀបចំដែនដី** | ការងារ១.១ ធ្វើការណែនាំអំពីផែនការរៀបចំដែនដីដល់អាជ្ញាធរខេត្ត | ១ ខែ |
| | ការងារ១.២ បង្កើតក្រុមការងារកសាងផែនការរៀបចំដែនដី | |
| | ការងារ១.៣ ពង្រឹងសមត្ថភាពដល់ក្រុមការងារកសាងផែនការរៀបចំដែនដី | |
| | ការងារ១.៤ ការកំណត់ និងគៀងគរការចូលរួមពីអ្នកពាក់ព័ន្ធ | |
| **ជំហានទី២ ការវិភាគស្ថានភាព** | ការងារ២.១ ការប្រមូលទិន្នន័យ និងការគ្រប់គ្រងទិន្នន័យ | ៩ ខែ |
| | ការងារ២.២ ការវិភាគទិន្នន័យ និងការផលិតផែនទី | |
| | ការងារ២.៣ ការពិនិត្យផ្ទៀងផ្ទាត់នៅថ្នាក់ស្រុក សិក្ខាសាលាវិភាគ និងធ្វើបច្ចុប្បន្នភាព | |
| | ការងារ២.៤ ការវិភាគស្ថាប័នថ្នាក់ខេត្ត | |
| | ការងារ២.៥ ការវិភាគទម្រង់លក្ខណៈដែនដីបច្ចុប្បន្នក្នុងដែនដីខេត្ត | |
| **ជំហានទី៣ កំណត់ចក្ខុវិស័យសម្រាប់អនាគត** | ការងារ៣.៣ កំណត់សេណារីយ៉ូអភិវឌ្ឍន៍សម្រាប់អនាគត | ២ខែ |
| | ការងារ៣.៤ ការកំណត់ចក្ខុវិស័យ និងគោលដៅអភិវឌ្ឍន៍រយៈពេលវែង | |
| **ជំហានទី៤ យុទ្ធសាស្រ្តអភិវឌ្ឍន៍ដែនដី** | ការងារ៤.១ យុទ្ធសាស្រ្តអភិវឌ្ឍន៍ដែនដី | ៦ខែ |
| | ការងារ៤.២ ធ្វើការសម្របយុទ្ធសាស្រ្តតាមវិស័យ និងធ្វើបច្ចុប្បន្នភាពផែនការតាមវិស័យ | |
| | ការងារ៤.៣ ការពិភាក្សាជាមួយអាជ្ញាធរខេត្ត | |
| **ជំហានទី៥ ការអនុវត្ត ត្រួតពិនិត្យ វាយតម្លៃ និងការធ្វើបច្ចុប្បន្នភាពផែនការ** | ការងារ៥.១ ការអនុវត្ត និងត្រួតពិនិត្យ | ១ខែ |
| | ការងារ៥.២ ការវាយតម្លៃ ការធ្វើបច្ចុប្បន្នភាព និងការធ្វើឲ្យមានភាពស៊ីគ្នានៃឧបករណ៍កសាងផែនការ | |
| **ជំហានទី៦ ការបញ្ចប់ដំណើរការកសាងផែនការ** | ការងារ៦.១ ការពិភាក្សាជាសាធារណៈចុងក្រោយជាមួយអ្នកពាក់ព័ន្ធទាំងអស់ | ៥ខែ |
| | ការងារ៦.២ ការរៀបចំរបាយការណ៍បច្ចេកទេសចុងក្រោយ | |
| | ការងារ៦.៣ ការបិទផ្សាយជាសាធារណៈ និងការគាំទ្រលើផែនការដោយក្រុមប្រឹក្សាខេត្ត | |
| | ការងារ៦.៤ ការឯកភាពលើផែនការដោយគណៈកម្មាធិការរៀបចំដែនដី និងនគរូបនីយកម្មថ្នាក់ជាតិ | |

***រូបភាព៣*** **៖** ដំណើរការកសាងផែនការរៀបចំដែនដីថ្នាក់ខេត្ត

## ៤.២ ផែនការប្រើប្រាស់ដី និងប្លង់គោលប្រើប្រាស់ដីថ្នាក់ក្រុង និងស្រុក

| | |
|---|---|
| ប្រភេទផែនការ | ប្លង់គោលប្រើប្រាស់ដីថ្នាក់ក្រុង/ស្រុក ជាផែនការៀបចំដែនដីយុទ្ធសាស្ត្រ។ វាធ្វើការពន្យល់ច្បាស់លាស់ត្រឹមត្រូវ និងស្របទៅនឹងផែនការរៀបចំដែនដីថ្នាក់ខេត្ត វាផ្តល់នូវការតម្រង់ទិសលម្អិតបន្ថែមទៀតសម្រាប់ការអភិវឌ្ឍដែនដី។ លើសពីនេះទៀត ប្លង់គោលប្រើប្រាស់ដីថ្នាក់ក្រុង/ស្រុក ផ្តល់នូវមូលដ្ឋានសម្រាប់ការរៀបចំផែនការប្រើប្រាស់ដីទីប្រជុំជនលម្អិត និងផែនការប្រើប្រាស់ថ្នាក់ឃុំលម្អិត។ |
| តួនាទី និងទំហំ | ប្លង់គោលប្រើប្រាស់ដីថ្នាក់ក្រុងជាមួយនឹងផែនការប្រើប្រាស់ដី ដែលបានធ្វើសមាហរណកម្មហើយនៅក្នុងតំបន់ទីប្រជុំជន ជាផែនការដ៏សំខាន់បំផុតសម្រាប់ការអភិវឌ្ឍទីប្រជុំជនរបស់ទីក្រុង ក្រុង ឬតំបន់ទីប្រជុំជន។ ជាមួយនឹងការកំណត់ឲ្យបានច្បាស់លាស់ និងការលើកឡើងពីតួនាទី និងមុខងាររបស់ទីក្រុងដូចដែលបានកំណត់នៅក្នុងផែនការរៀបចំដែនដីថ្នាក់ខេត្ត ប្លង់គោលប្រើប្រាស់ដី គឺជាកិច្ចការដ៏សំខាន់សម្រាប់ការគ្រប់គ្រងនគរូបនីយកម្ម និងការអភិវឌ្ឍទីប្រជុំជនប្រកបដោយចីរភាព។<br><br>ប្លង់គោលប្រើប្រាស់ដីថ្នាក់ក្រុង កំណត់ពីប្រភេទប្រើប្រាស់ដីទូទៅ (តំបន់ដែលអាចសាងសង់បាន តំបន់កម្រិតការសាងសង់ និងតំបន់មិនអាចសាងសង់បាន) រួមទាំងការចាត់ចែងជាយុទ្ធសាស្ត្រនៃការប្រើប្រាស់ដីទៅតាមប្រភេទសំខាន់ៗ។ វាបញ្ចូលទាំងការអភិវឌ្ឍប្រព័ន្ធបៃតង និងបណ្តាញទឹក ប្រព័ន្ធដឹកជញ្ជូន ក៏ដូចជាហេដ្ឋារចនាសម្ព័ន្ធសង្គម និងរូបវន្ត ទោះបីជាយ៉ាងណាក៏ដោយក៏ត្រូវការនូវផែនការលម្អិតតាមវិស័យ ដើម្បីឲ្យកាន់តែមានភាពជាក់លាក់ និងបំពេញបន្ថែមដល់ប្លង់គោលប្រើប្រាស់ដី ជាពិសេសទាក់ទងទៅនឹងការដឹកជញ្ជូន និងហេដ្ឋារចនាសម្ព័ន្ធរូបវន្ត។ តំបន់អាទិភាពមួយចំនួនអាចនឹងជាលទ្ធផលដែលកើតចេញដោយផ្ទាល់ពីប្លង់គោលប្រើប្រាស់ដីដែលវាជាចំណែកមួយរបស់ប្លង់លម្អិតនគរូបនីយកម្ម។ ផែនការប្រើប្រាស់ដី នឹងបំពេញបន្ថែមដល់ប្លង់គោលប្រើប្រាស់ដី ដោយវាផ្តល់នូវក្របខ័ណ្ឌគតិយុត្តិ (បទបញ្ញត្តិ) |

សម្រាប់ការសាងសង់ និងប្រើប្រាស់ដីតំបន់ជាយក្រុង និងទីប្រជុំជន។ វារួមមានបទបញ្ញាត្តិសម្រាប់ទេសភាពទីក្រុង និងរចនាសម្ព័ន្ធសាងសង់ដូចជា ផលធៀបផ្ទៃក្រឡាបាតសំណង់ធៀបនិងផ្ទៃដីឡូត៍ សន្ទស្សន៍ប្រើប្រាស់ដី និងកម្ពស់អគារ។

ប្លង់គោលប្រើប្រាស់ដីថ្នាក់ស្រុក មានសមាសភាគប្រហាក់ប្រហែលគ្នាទៅនឹងប្លង់គោលប្រើប្រាស់ដីថ្នាក់ក្រុង នៅពេលដែលវាប្រែក្លាយទៅជាមជ្ឈមណ្ឌលទីប្រជុំជនរដ្ឋបាល ដូចគ្នានេះដែរការកំណត់ពីមុខងារនិងតួនាទីរបស់មជ្ឈមណ្ឌលទីប្រជុំជន គឺអាស្រ័យទៅលើផែនការរៀបចំដែនដីថ្នាក់ខេត្ត។ ស្រុកជាច្រើននៅក្នុងប្រទេសកម្ពុជា ភាគច្រើនជាតំបន់ជនបទ និងតំបន់ពាក់កណ្តាលជនបទ និងទីប្រជុំជន។ ដូចនេះហើយ ប្លង់គោលប្រើប្រាស់ដីថ្នាក់ស្រុក បង្កើតឡើងដោយផ្អែកទៅលើការណែនាំតម្រង់ទិស ពីផែនការរៀបចំដែនដីថ្នាក់ខេត្ត ប៉ុន្តែវាមានភាពលម្អិតជាងផែនការថ្នាក់ខេត្តនៅពេលដែលធ្វើការបង្កើតនូវយុទ្ធសាស្ត្រសម្រាប់ការគ្រប់គ្រងធនធានធម្មជាតិ និងដីធ្លី។ ស្នូលសំខាន់របស់យុទ្ធសាស្ត្រទាំងនេះ គឺវាស្របជាមួយនឹងការគ្រប់គ្រងទីជម្រាលប្រកបដោយចីរភាព ក្នុងគោលបំណងធ្វើឲ្យមាននិរន្តរភាពប៉ុន្តែធ្វើការប្រើប្រាស់តំបន់កសិកម្មប្រកបដោយផ្លែផ្កា និងការប្រើប្រាស់ដែលមានការការពារដល់ធនធានជលផលនិងព្រៃឈើ។

ប្លង់គោលប្រើប្រាស់ដីថ្នាក់ស្រុក ក៏បង្ហាញផងដែរពីកន្លែងដែលចាំបាច់បំផុតដែលត្រូវធ្វើការកសាងផែនការប្រើប្រស់ដីថ្នាក់ឃុំ និងមានប្រសិទ្ធភាព ហើយផែនការប្រើប្រាស់ដីថ្នាក់ឃុំនេះ នឹងជួយដល់ការប្រើប្រាស់ដីឲ្យកាន់តែជាក់លាក់ និងបំពេញបន្ថែមដល់ប្លង់គោលប្រើប្រាស់ដីថ្នាក់ស្រុក។

| | |
|---|---|
| រយៈពេល | ១៥ ឆ្នាំ |
| មាត្រដ្ឋាន | ១/៥០ ០០០ ទៅ ១/២៥ ០០០ |
| សមត្ថកិច្ចនិងស្ថាប័ន | គណៈកម្មាធិការរៀបចំដែនដី និងនគរូបនីយកម្មថ្នាក់ក្រុង/ស្រុកជាអ្នកផ្តួចផ្តើមដំណើរការកសាងផែនការក្រោមការគ្រប់គ្រងដឹកនាំរបស់ក្រុមប្រឹក្សាក្រុង/ |

ស្រុក។ ជាទូទៅ គណៈកម្មាធិការមិនពាក់ព័ន្ធដោយផ្ទាល់ទៅនឹងដំណើរការកសាងផែនការនោះទេ ដូច្នេះក្រុមការងាររៀបចំដែនដី និងនគរូបនីយកម្មថ្នាក់ក្រុង/ស្រុកត្រូវបានបង្កើតឡើងដើម្បីអនុវត្តដំណើរការការងារកសាងផែនការ។ ក្រុមប្រឹក្សាក្រុង/ស្រុក ធ្វើការសម្របសម្រួលដល់ដំណើរការកសាងផែនការទាំងមូល និងឯកភាពទៅលើសេចក្ដីព្រាងប្លង់គោលប្រើប្រាស់ដី។ បន្ទាប់មកប្លង់គោលប្រើប្រាស់ដីនេះ ត្រូវបញ្ជូនមកក្រុមប្រឹក្សាខេត្តតាមរយៈគណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្ម ដើម្បីសូមការយល់ព្រមលើប្លង់គោល។ បន្ទាប់ពីមានការឯកភាព និងយល់ព្រមពីក្រុមប្រឹក្សា និងគណៈកម្មាធិការហើយនោះ ប្លង់គោលនេះនឹងត្រូវដាក់ជូនគណៈកម្មាធិការរៀបចំដែនដី និងនគរូបនីយកម្មថ្នាក់ជាតិដើម្បីធ្វើការអនុម័តចុងក្រោយលើប្លង់គោល (មើលរូបភាព ៤)។




**រូបភាព៤៖** រចនាសម្ព័ន្ធស្ថាប័នសម្រាប់ការកសាងប្លង់គោលប្រើប្រាស់ដីថ្នាក់ក្រុង/ស្រុក

ដំណើរការ

កសាងផែនការរួម

ដំណើរការកសាងប្លង់គោលប្រើប្រាស់ដីមាន ៩ ជំហានសំខាន់ៗ ដែលនឹងត្រូវធ្វើឡើងក្នុងរយៈពេលប្រមាណជា ២៦ខែ (មើលរូបភាព៥) ។ នេះជារយៈពេលមួយដែលការងារនេះ ត្រូវបានធ្វើឡើងប្រកបដោយភាពរលូន គ្មានការរំខាននៅក្នុងដំណើរការ ប៉ុន្តែករណីដែលការអនុវត្តការងារប្រព្រឹត្តទៅដោយភាពរលូនគឺជាករណីមួយដ៏កម្រនៅពេលដែលធ្វើការអនុវត្តការងារជាក់ស្តែង។ ការចែកដំណើរការជា ៩ ជំហាន និងការកំណត់រយៈពេលទៅលើជំហាននីមួយៗនេះ គឺផ្អែកទៅលើសេចក្តីសម្រេចស្តីពីនីតិវិធីលម្អិតនៃការរៀបចំប្លង់គោលប្រើប្រាស់ដីនិងផែនការប្រើប្រាស់ដីថ្នាក់ក្រុង ស្រុក ខណ្ឌ ដែលប្រកាសដោយគណៈកម្មាធិការរៀបចំដែនដី និងនគរូបនីយកម្មថ្នាក់ជាតិ។

| ជំហាន | ការងារ | រយៈពេល |
|---|---|---|
| ផ្នែក ក - ការពិពណ៌នា និងការអនុម័តលើប្លង់គោលប្រើប្រាស់ដីថ្នាក់ក្រុង/ស្រុក | | |
| ជំហានទី១ ការរៀបចំ និងការចាប់ផ្តើមដំណើរការកសាងប្លង់គោលប្រើប្រាស់ដីថ្នាក់ក្រុង/ស្រុក | ការងារ ១.១ ទំហំ និងការចាប់ផ្តើមការងារ | ៣០ ថ្ងៃ |
| | ការងារ ១.២ ការបង្កើតគណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្ម និងក្រុមការងារ | |
| | ការងារ ១.៣ ការកំណត់ និងគៀងគរការចូលរួមពីអ្នកពាក់ព័ន្ធនៅក្នុងសិក្ខាសាលាកសាងប្លង់គោលប្រើប្រាស់ដីលើកដំបូងជាមួយអ្នកពាក់ព័ន្ធ | |
| | ការងារ ១.៤ ការកសាងសមត្ថភាពត្រូវការវាយតម្លៃ បង្កើតក្រុមការងារ និងធ្វើផែនការការងារ | |
| ជំហានទី២ ការប្រមូលទិន្នន័យ និងការគ្រប់គ្រងទិន្នន័យ | ការងារ ២.១ ការចុះប្រមូលទិន្នន័យ និងព័ត៌មាន | ១៥០ ថ្ងៃ |
| | ការងារ ២.២ ការគ្រប់គ្រងជាតាបេស (ឃ្លាំងផ្ទុកទិន្នន័យ) ទិន្នន័យភូមិសាស្ត្រ | |
| ជំហានទី៣ ការវិភាគស្ថានភាព និងកំណត់ចក្ខុវិស័យសម្រាប់អនាគត | ការងារ ៣.១ការវិភាគទិន្នន័យ និងការផលិតផែនទី | ៩០ ថ្ងៃ |
| | ការងារ ៣.២ ការវិភាគបរិស្ថាន | |
| | ការងារ ៣.៣ ការវិភាគការគ្រប់គ្រងដីធ្លីនៅថ្នាក់ឃុំ/សង្កាត់ | |
| | ការងារ ៣.៤ ការវិភាគពីអភិបាលកិច្ចនិងការគ្រប់គ្រងការប្រើប្រាស់ដីដោយ គ.ដ.ន ថ្នាក់ក្រុង/ស្រុក | |
| | ការងារ ៣.៥ ការធ្វើបទបង្ហាញ និងការពិគ្រោះយោបល់ពីការវិភាគស្ថានភាពនៅក្នុងសិក្ខាសាលាកសាងប្លង់គោលប្រើប្រាស់ដីលើកទី២ ជាមួយអ្នកពាក់ព័ន្ធ | |
| | ការងារ ៣.៦ ការវិភាគសេណារីយ៉ូ | |
| | ការងារ ៣.៧ ពិភាក្សាពីសេណារីយ៉ូ កំណត់គោលដៅអភិវឌ្ឍន៍រយៈពេលវែងនិងចក្ខុវិស័យអភិវឌ្ឍន៍ជាមួយនឹង គ.ដ.ន ថ្នាក់ក្រុង/ស្រុក | |
| | ការងារ ៣.៨ កែសម្រួលដល់គោលដៅអភិវឌ្ឍន៍រយៈពេលវែង គោលបំណងយុទ្ធសាស្ត្រនិងចក្ខុវិស័យនៅក្នុងសិក្ខាសាលាកសាងប្លង់គោលប្រើប្រាស់ដីលើកទី៣ ជាមួយអ្នកពាក់ព័ន្ធ | |
| | ការងារ ៣.៩ ធ្វើការបញ្ចប់ និងចងក្រងឯកសារលទ្ធផលពីជំហានទី៣ | |

| | | |
|---|---|---|
| **ជំហានទី៤ ការរៀបចំសេចក្តីព្រាងប្លង់គោលប្រើប្រាស់ដី** | ការងារ ៤.១ ពិពណ៌នាលម្អិតពីតារាងយុទ្ធសាស្ត្រ<br>ការងារ ៤.២ ពិពណ៌នាលម្អិតពីគំរូអភិវឌ្ឍន៍ដែនដីជាមួយនឹង គ.ដ.ន ថ្នាក់ក្រុង/ស្រុក<br>ការងារ ៤.៣ រៀបចំសេចក្តីព្រាងយុទ្ធសាស្ត្រ និងផែនការតាមប្រធានបទសំខាន់ៗនៅថ្នាក់ក្រុង/ស្រុក<br>ការងារ ៤.៤ រៀបចំសេចក្តីព្រាងប្លង់គោលប្រើប្រាស់ដី | ១២០ ថ្ងៃ |
| **ជំហានទី៥ ពិនិត្យលើសេចក្តីព្រាងប្លង់គោលប្រើប្រាស់ដីដោយអ្នកពាក់ព័ន្ធថ្នាក់ក្រុង/ស្រុក** | ការងារ ៥.១ ពិភាក្សាទៅលើយុទ្ធសាស្ត្រសមាហរណកម្មអភិវឌ្ឍន៍ដែនដី និងសេចក្តីព្រាងប្លង់គោលប្រើប្រាស់ដីជាមួយនឹងអាជ្ញាធរឃុំ/សង្កាត់<br>ការងារ ៥.២ កែតម្រូវយុទ្ធសាស្ត្រសមាហរណកម្មអភិវឌ្ឍន៍ដែនដី និងសេចក្តីព្រាងប្លង់គោលប្រើប្រាស់ដីនៅក្នុងសិក្ខាសាលាកសាងប្លង់គោលប្រើប្រាស់ដីលើកទី៤ ជាមួយអ្នកពាក់ព័ន្ធ | ៩០ ថ្ងៃ |
| **ជំហានទី៦ ការបិទផ្សាយជាសាធារណ:** | ការងារ ៦.១ រៀបចំរបាយការណ៍បច្ចេកទេសចុងក្រោយ<br>ការងារ ៦.២ ការបិទផ្សាយជាសាធារណ: (សេចក្តីព្រាងប្លង់គោលប្រើប្រាស់ដី) | ៦០ ថ្ងៃ |
| **ជំហានទី៧ ពិនិត្យលើរបាយការណ៍បច្ចេកទេស** | ការងារ ៧.១ បទបង្ហាញចុងក្រោយដល់អាជ្ញាធរថ្នាក់ខេត្ត និងការកែសម្រួលឡើងវិញ<br>ការងារ ៧.២ បទបង្ហាញចុងក្រោយដល់ថ្នាក់ជាតិ និងការកែសម្រួលឡើងវិញ | ៦០ ថ្ងៃ |
| **ជំហានទី៨ ការកំណត់គម្រោងអាទិភាព** | ការងារ ៨.១ កំណត់គម្រោងអាទិភាព | ៦០ ថ្ងៃ |
| **ជំហានទី៩ ការសម្រេចលើប្លង់គោលប្រើប្រាស់ដី** | ការងារ ៩.១ ដាក់ប្លង់គោលប្រើប្រាស់ដីជូនអាជ្ញាធរខេត្ត និងក្រុង/ស្រុក សម្រាប់ការឯកភាពគាំទ្រចុងក្រោយ<br>ការងារ ៩.២ ដាក់ប្លង់គោលប្រើប្រាស់ដីជូនថ្នាក់ជាតិ សម្រាប់ការអនុម័តចុងក្រោយ | ១២៥ ថ្ងៃ |
| | សរុប | ៧៨៥ ថ្ងៃ |

**រូបភាព ៥ ៖** ដំណើរការកសាងផែនការរួមសម្រាប់ប្លង់គោលប្រើប្រាស់ដីថ្នាក់ក្រុង/ស្រុក

ដំណើរការកសាងផែនការរៀបចំដែនដីក៏មាន ៩ ជំហានដូចគ្នាដែរ ដែលនឹងត្រូវចំណាយពេលប្រមាណជា ២២ ខែដើម្បីធ្វើការងារ (រូបភាព៦)។ ការបែងចែកដំណើរការជា ៩ ជំហានគឺធ្វើឡើងដោយផ្អែកទៅលើសេចក្តីសម្រេចស្តីពីនីតិវិធីលម្អិតនៃការរៀបចំប្លង់គោលប្រើប្រាស់ដី និងផែនការប្រើប្រាស់ដីថ្នាក់ក្រុង ស្រុក ខណ្ឌ ដែលអនុម័តដោយ គ.ដ.ន.ជ (គ.ដ.ន.ជ ២០១៣)។ ទោះបីជាយ៉ាងណាក៏ដោយ ដោយផែនការប្រើប្រាស់ដីផ្អែកទៅលើនិងធ្វើលម្អិតបន្តចេញពីដំណើរការកសាងប្លង់គោលប្រើប្រាស់ដី ការងារជាច្រើនដែលបានធ្វើហើយនៅក្នុងដំណើរការកសាងប្លង់គោល មិនចាំបាច់ធ្វើឡើងវិញម្តងទៀតដដែលៗសម្រាប់ផែនការប្រើប្រាស់ដីនោះទេ ដូច្នេះដំណើរការកសាងផែនការប្រើប្រាស់ដី គឺខ្លីជាងដំណើរការកសាងប្លង់គោលប្រើប្រាស់ដី។

| ជំហាន | ការងារ | រយៈពល |
|---|---|---|
| ផ្នែក ខ - ការពិពណ៌នា និងការអនុម័តលើផែនការប្រើប្រាស់ដីថ្នាក់ក្រុង/ស្រុក | | |
| ជំហានទី១ ការរៀបចំ និងការចាប់ផ្តើម | ការងារ ១.១ ទំហំ និងការចាប់ផ្តើមផែនការប្រើប្រាស់ដី<br>ការងារ ១.២ ការផ្សព្វផ្សាយ និងគៀងគរការចូលរួមពីអ្នកពាក់ព័ន្ធនៅក្នុងសិក្ខាសាលាកសាងផែនការប្រើប្រាស់ដីលើកទី៥ ជាមួយអ្នកពាក់ព័ន្ធ (បន្តពីសិក្ខាសាលាប្លង់គោលប្រើប្រាស់ដី) | ១០ ថ្ងៃ |
| ជំហានទី២ ការប្រមូលទិន្នន័យ និងការគ្រប់គ្រងទិន្នន័យ | ការងារ ២.១ ការចុះប្រមូលទិន្នន័យ និងព័ត៌មាន | ៥០ ថ្ងៃ |
| ជំហានទី៣ ការវិភាគទិន្នន័យ | ការងារ ៣.១ ធ្វើឲ្យប្រសើរឡើងដល់ទិន្នន័យភូមិសាស្ត្រសម្រាប់តំបន់ប្រើប្រាស់ដី<br>ការងារ ៣.២ វិភាគទេសភាពទីក្រុងដែលមានស្រាប់ និងរចនាសម្ព័ន្ធសាងសង់<br>ការងារ ៣.៣ វិភាគបណ្តាញផ្លូវនៅមូលដ្ឋាន (ជាជម្រើស) | ៩០ ថ្ងៃ |
| ជំហានទី៤ ការរៀបចំសេចក្តីព្រាងផែនការប្រើប្រាស់ដី | ការងារ ៤.១ កំណត់បទបញ្ញត្តិប្រភេទប្រើប្រាស់ប្រាស់ដី (មុខងារ/បទបញ្ញត្តិបែងចែកតំបន់ប្រើប្រាស់ដី) ជាមួយនឹង គ.ដ.ន ថ្នាក់ក្រុង/ស្រុក<br>ការងារ ៤.២ កំណត់បទបញ្ញត្តិសាងសង់សម្រាប់អនាគត (បទបញ្ញត្តិបែងចែកតំបន់ទៅតាមទម្រង់លក្ខណៈប្រើប្រាស់) ជាមួយនឹង គ.ដ.ន ថ្នាក់ក្រុង/ស្រុក | ១២០ ថ្ងៃ |
| ជំហានទី៥ ពិនិត្យលើសេចក្តីព្រាងផែនការប្រើប្រាស់ដី | ការងារ ៥.១ ពិគ្រោះយោបល់ជាមួយនឹងអាជ្ញាធរឃុំ/សង្កាត់លើសេចក្តីព្រាងផែនការប្រើប្រាស់ដី<br>ការងារ ៥.២ កែសម្រួលដល់សេចក្តីព្រាងផែនការប្រើប្រាស់ដី នៅក្នុងសិក្ខាសាលាកសាងផែនការប្រើប្រាស់ដីលើកទី៦ ជាមួយអ្នកពាក់ព័ន្ធ | ៩០ ថ្ងៃ |
| ជំហានទី៦ ការបិទផ្សាយជាសាធារណៈ | ការងារ ៦.១ រៀបចំរបាយការណ៍បច្ចេកទេសចុងក្រោយ<br>ការងារ ៦.២ បិទផ្សាយជាសាធារណៈ (សេចក្តីព្រាងផែនការប្រើប្រាស់ដី) | ៦០ ថ្ងៃ |
| ជំហានទី៧ ការពិនិត្យលើរបាយការណ៍បច្ចេកទេស | ការងារ ៧.១ បទបង្ហាញចុងក្រោយដល់អាជ្ញាធរថ្នាក់ខេត្ត និងការកែសម្រួលឡើងវិញ<br>ការងារ ៧.២ បទបង្ហាញចុងក្រោយដល់ថ្នាក់ជាតិ និងការកែសម្រួលឡើងវិញ | ៦០ ថ្ងៃ |
| ជំហានទី៨ ការកំណត់គម្រោងអាទិភាព | ការងារ ៨.១ កំណត់គម្រោងអាទិភាព | ៦០ ថ្ងៃ |
| ជំហានទី៩ ការសម្រេចលើផែនការប្រើប្រាស់ដី | ការងារ ៩.១ ដាក់ផែនការប្រើប្រាស់ដីជូនអាជ្ញាធរខេត្ត និងក្រុង/ស្រុក សម្រាប់ការឯកភាពគាំទ្រចុងក្រោយ<br>ការងារ ៩.២ ដាក់ផែនការប្រើប្រាស់ដីជូនថ្នាក់ជាតិ សម្រាប់ការអនុម័តចុងក្រោយ | ១២៥ ថ្ងៃ |
| | សរុប | ៦៦៥ ថ្ងៃ |

រូបភាព ៦ ៖ ដំណើរការកសាងផែនការរួមសម្រាប់ផែនការប្រើប្រាស់ដីថ្នាក់ក្រុង/ស្រុក

## ៤.៣ ផែនការប្រើប្រាស់ដីឃុំ/សង្កាត់

| | |
|---|---|
| ប្រភេទផែនការ | ផែនការប្រើប្រាស់ដីឃុំ/សង្កាត់សំដៅដល់ផែនការប្រើប្រាស់ដីនៅក្នុងឃុំ/សង្កាត់ ហើយវាគ្របដណ្តប់ទាំងដីកម្មសិទ្ធិរបស់រដ្ឋ និងដីកម្មសិទ្ធិឯកជន (រាជរដ្ឋាភិបាលកម្ពុជា ២០០៨b)។ ផែនការនេះជួយគាំទ្រដល់ការរៀបចំ និងការអនុវត្តផែនការអភិវឌ្ឍឃុំ/សង្កាត់ រយៈពេល៥ឆ្នាំ និងផែនការវិនិយោគបីឆ្នាំរំកិល។ |
| តួនាទីនិងទំហំ | ផែនការប្រើប្រាស់ដីឃុំ/សង្កាត់ គួរស្របជាមួយនឹងផែនការអភិវឌ្ឍន៍ឃុំ/សង្កាត់ និងចង្អុលបង្ហាញទិសដៅអភិវឌ្ឍន៍ដែនដី និងគម្រោងដែលប្រមើលមើលទុកនៅក្នុងផែនការអភិវឌ្ឍន៍ឃុំ/សង្កាត់រយៈពេល៥ឆ្នាំ និងផែនការវិនិយោគបីឆ្នាំរំកិល ហើយវាផ្អែកទៅលើធនធានជាក់ស្តែងឬលក្ខណៈសម្បត្តិតំបន់ធ្វើផែនការ។ ផែនការប្រើប្រាស់ដីឃុំ/សង្កាត់ គឺជាកិច្ចការដ៏មានសារៈសំខាន់មួយសម្រាប់ក្រុមប្រឹក្សាឃុំ/សង្កាត់ក្នុងការធ្វើការគ្រប់គ្រង និងប្រើប្រាស់ធនធានធម្មជាតិ និងធនធានដីធ្លីប្រកបដោយប្រសិទ្ធភាព ដើម្បីគាំទ្រដល់ការអភិវឌ្ឍសេដ្ឋកិច្ចសង្គមប្រកបដោយសមធម៌ និងនិរន្តរភាពក្នុងការចូលរួមចំណែកកាត់បន្ថយភាពក្រីក្រ។ |

ទំហំនៃផែនការប្រើប្រាស់ដីឃុំ/សង្កាត់ (Dummer 2008) ៖

- ការវិភាគពីស្ថានភាពដែលមានស្រាប់នៅក្នុងឃុំ។ ធ្វើការកែតម្រូវ និងធ្វើបច្ចុប្បន្នភាពគម្របដីបច្ចុប្បន្ន/ផែនទីប្រើប្រាស់ដី (រួមមានហេដ្ឋារចនាសម្ព័ន្ធ សម្បទានដី តំបន់ការពារ សហគមន៍ព្រៃឈើ។ល។)
- វិភាគពីសក្តានុពល (សម្បទានដីសេដ្ឋកិច្ច តំបន់សម្បទានដីសង្គមកិច្ច លក្ខខណ្ឌទីផ្សារទន់ខ្សោយ។ល។) និងបញ្ហា (សម្បទានដីសេដ្ឋកិច្ច ដីគុណភាពអន់ ទំនាស់ដីធ្លី លក្ខខណ្ឌទីផ្សារទន់ខ្សោយ ប្រព័ន្ធហេដ្ឋារចនាសម្ព័ន្ធមិនគ្រប់គ្រាន់)។
- ផែនការប្រើប្រាស់ដីឃុំ/សង្កាត់មានបញ្ចូលនូវជម្រើសសម្រាប់ការប្រើប្រាស់ដីនាពេលអនាគត។

- ផែនការអនុវត្ត (ជាផ្នែករបស់ផែនការអភិវឌ្ឍន៍ឃុំ/សង្កាត់រយៈពេល៥ឆ្នាំ និង កម្មវិធីវិនិយោគ៣ឆ្នាំរំកិល) កន្លែងដែលបានកំណត់ពីគម្រោងអភិវឌ្ឍន៍ នាពេលអនាគតនៅលើផែនទីប្រើប្រាស់ដីបច្ចុប្បន្នដោយភ្ជាប់ទៅនឹងជំហាន និងពេលវេលាអនុវត្តគម្រោង។

ផែនទី បញ្ហា/មូលហេតុ/ដំណោះស្រាយ គឺជាស្នូលសំខាន់នៅក្នុងដំណើរការ កសាងផែនការប្រើប្រាស់ដីឃុំ/សង្កាត់ (Dummer 2008)។ វាបង្ហាញនូវបញ្ហា ផ្សេងៗ ដែលបានរកឃើញដោយអ្នកភូមិ និងឃុំ ក្នុងកំឡុងពេលវិភាគពីបញ្ហា/ មូលហេតុ/ដំណោះស្រាយ និងកំឡុងពេលគូរពីលើផែនទីប្រើប្រាស់ដីសាមញ្ញ បច្ចុប្បន្ន ដោយមានគូរនូវនិមិត្តសញ្ញាដែលផ្គូរផ្គងភ្ជាប់ទៅនឹងតារាងបញ្ហា/ មូលហេតុ/ដំណោះស្រាយដែលរៀបរាប់ពីលក្ខណៈសម្បត្តិ ទំហំ និងមូលហេតុ របស់បញ្ហានីមួយៗ។

| | |
|---|---|
| រយៈពេល | ១០ ទៅ២០ ឆ្នាំ |
| មាត្រដ្ឋាន | ពី ១/១០ ០០០ ទៅ ១/៣០ ០០០ អាស្រ័យទៅលើទំហំរបស់ឃុំ |
| សមត្ថកិច្ច និងស្ថាប័ន | ការកសាងផែនការប្រើប្រាស់ដីឃុំ/សង្កាត់ ស្ថិតនៅក្រោមដែនសមត្ថកិច្ចក្រុម ប្រឹក្សាឃុំ ដោយវាមានទំនាក់ទំនងយ៉ាងជិតស្និទ្ធិជាមួយនឹងដំណើរការកសាង ផែនការអភិវឌ្ឍន៍ឃុំរយៈពេល៥ឆ្នាំ/កម្មវិធីវិនិយោគ៣ឆ្នាំរំកិល។ ផែនការនេះ នឹងត្រូវដាក់ជូនដល់ក្រុមការងារថ្នាក់ស្រុក ដើម្បីធ្វើការពិនិត្យ កែតម្រូវ និងដាក់ ជូនដល់គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់ខេត្ត ដើម្បីអនុម័តទៅលើផែនការ នេះ (មើលរូបភាព៧)។ មូលហេតុដែលដំណើរការរបស់ផែនការនេះមានភាព ខុសប្លែកគ្នាតិចតួចជាមួយនឹងផែនការរៀបចំដែនដីថ្នាក់ខេត្ត និងផែនការប្រើ ប្រាស់ដីនិងប្លង់គោលប្រើប្រាស់ដីថ្នាក់ក្រុង/ស្រុក គឺថាដំណើរការកសាង ផែនការប្រើប្រាស់ដីឃុំ/សង្កាត់ ត្រូវបានធ្វើការកសាងឡើង និងត្រូវបានបំលែង ជាទម្រង់ក្របខ័ណ្ឌច្បាប់យ៉ាងល្អប្រសើរ មុនពេលដែលគោលនយោបាយស្តីពី ការកសាងផែនការរៀបចំដែនដីត្រូវបានបង្កើតឡើង។ |




**រូបភាព ៧ ៖** រចនាសម្ព័ន្ធស្ថាប័នសម្រាប់ផែនការប្រើប្រាស់ដីថ្នាក់ឃុំ

ដំណើរការ

កសាងផែនការរួម — ដំណើរការកសាងផែនការប្រើប្រាស់ដីឃុំ/សង្កាត់ គឺមានភាពខុសប្លែកគ្នាតិចតួចពីផែនការរៀបចំដែនដីថ្នាក់ខេត្ត និងប្លង់គោលប្រើប្រាស់ដីថ្នាក់ក្រុង/ស្រុក ដោយវាត្រូវបានបញ្ចូលទាំងស្រុងទៅក្នុងដំណើរការផែនការអភិវឌ្ឍន៍ឃុំ/សង្កាត់រយៈពេល៥ឆ្នាំនិងកម្មវិធីវិនិយោគ៣ឆ្នាំរំកិល (រូបភាព៨) (ក្រ.ដនស ២០០៧)។

| ជំហានកសាងផែនការប្រើប្រាស់ដីឃុំ/សង្កាត់ | ផែនការអភិវឌ្ឍន៍ឃុំ/សង្កាត់ (CDP) | កម្មវិធីវិនិយោគឃុំសង្កាត់ (CIP) |
|---|---|---|
| **០. ការរៀបចំ**<br>ផែនទីប្រើប្រាស់ដីសម្រាប់ការប្រើប្រាស់របស់ក្រុមប្រឹក្សាឃុំនៅក្នុង CDP/CIP | | |
| **១. ធ្វើការផ្ទៀងផ្ទាត់ដោយឃុំ/សង្កាត់**<br>ក្រុមប្រឹក្សាឃុំសង្កាត់ធ្វើការផ្ទៀងផ្ទាត់ និងកែតម្រូវផែនទីប្រើប្រាស់ដីបច្ចុប្បន្ន | **សេចក្តីព្រាងក្របខ័ណ្ឌអភិវឌ្ឍន៍ (ជំហាន១ CDP) ៖** វិភាគនិងកំណត់បញ្ហាអភិវឌ្ឍន៍ និងដំណោះស្រាយដែលអាចធ្វើទៅបាន (ប្រជុំភូមិ និងបង្រួមបញ្ចូលគ្នានៅថ្នាក់ឃុំ) | |
| **២.កសាងផែនទីបញ្ហា/មូលហេតុ/ដំណោះស្រាយ ៖** ធ្វើការរៀបចំផែនទីដោយផ្អែកលើលទ្ធផលពីការវាយតម្លៃបញ្ហា/មូលហេតុ/ដំណោះស្រាយ | **សេចក្តីព្រាងក្របខ័ណ្ឌអភិវឌ្ឍន៍ ( ជំហាន១ CDP) ៖** វិភាគនិងកំណត់បញ្ហាអភិវឌ្ឍន៍ និងដំណោះស្រាយដែលអាចធ្វើទៅបាន (ប្រជុំភូមិ និង បង្រួមបញ្ចូលគ្នានៅថ្នាក់ឃុំ) | |
| **៣.កសាងផែនទីគោលបំណងអភិវឌ្ឍន៍ CDP**<br>រៀបចំផែនទីគម្រោង (រួមទាំងតម្រូវការសម្រាប់កសាងផែនការប្រើប្រាស់ដី) | **សេចក្តីព្រាងក្របខ័ណ្ឌអភិវឌ្ឍន៍ ( ជំហាន១ CDP) ៖**<br>បង្រួមបញ្ចូលគ្នានៅថ្នាក់ឃុំ | |
| **៤.ធ្វើបញ្ចប់ផែនទីគាំទ្រ**<br>ផែនទីគម្រោង និងផែនទីបញ្ហា/មូលហេតុ/ដំណោះស្រាយសម្រេចចុងក្រោយ សម្រាប់ផែនការអភិវឌ្ឍន៍ឃុំ | **សេចក្តីព្រាងក្របខ័ណ្ឌអភិវឌ្ឍន៍ ( ជំហាន៣ CDP)** | |
| **៥.ជួយដល់ការរៀបចំគម្រោង CIP**<br>ផែនទីគម្រោង និងផែនទីបញ្ហា/មូលហេតុ/ដំណោះស្រាយសម្រេចចុងក្រោយ សម្រាប់ផែនការអភិវឌ្ឍន៍ឃុំ | | ការកំណត់និងការពិភាក្សាពិគ្រោះយោបល់របស់ប្រជាពលរដ្ឋពីគម្រោង CIP |
| **៦.គាំទ្រដល់ការប្រមូលផ្តុំគម្រោងបញ្ចូលគ្នា**<br>ផែនទីគម្រោងសម្រេចចុងក្រោយ (រួមទាំងគម្រោងកសាងផែនការប្រើប្រាស់ដី) | | ប្រមូលផ្តុំសំណើរ និងដាក់បញ្ជូនគម្រោង CIP ទៅថ្នាក់ខេត្ត |
| **៧. គាំទ្រដល់បទបង្ហាញក្នុងសិក្ខាសាលាសមាហរណកម្មថ្នាក់ស្រុក** | | សិក្ខាសាលាសមាហរណកម្មថ្នាក់ស្រុក |
| **៨. ការធ្វើផែនទីសម្រេចចុងក្រោយសម្រាប់ក្រុមប្រឹក្សាពិនិត្យ** | | ក្រុមប្រឹក្សាឃុំអនុម័ត CIP និងចាប់ផ្តើមប្រតិបត្តិការ |
| **៩. ការគាំទ្រ ការត្រួតពិនិត្យ និងវាយតម្លៃ**<br>ធ្វើការបណ្តុះបណ្តាលគាំទ្រដល់ក្រុមប្រឹក្សាឃុំ/គណៈកម្មាធិការកសាងផែនការនិងថវិកាឃុំ/សង្កាត់ ពីការប្រើប្រាស់ផែនទីក្នុងការត្រួតពិនិត្យ និងវាយតម្លៃ | **ការវាយតម្លៃ** | ធ្វើការត្រួតពិនិត្យ និងផ្តល់អនុសាសន៍ (យោបល់) ដល់ក្រុមប្រឹក្សាឃុំ |
| **១០. ការគាំទ្រដល់ការអនុវត្តគម្រោងផែនការប្រើប្រាស់ដី ៖** គាំទ្រដល់ការរៀបចំផែនការប្រើប្រាស់ដីប្រតិបត្តិ | | ក្រុមប្រឹក្សាឃុំអនុម័ត CIP និងចាប់ផ្តើមប្រតិបត្តិការ (ក្នុងករណីកន្លែងណាដែលគម្រោងផែនការប្រើប្រាស់ដីត្រូវបានបញ្ចូលទៅក្នុង CIP) |
| **១១. ប្រមូលទិន្នន័យបញ្ចូលទៅក្នុងដាតាបេស (ឃ្លាំងផ្ទុកទិន្នន័យ)**<br>ថ្នាក់ឃុំ ថ្នាក់ស្រុក និងថ្នាក់ខេត្ត | | |

***រូបភាព ៨ ៖*** ដំណើរការកសាងផែនការរួមសម្រាប់ផែនការប្រើប្រាស់ដីឃុំ/សង្កាត់

# ៥. គោលការណ៍សំខាន់ៗនៃការកសាងផែនការរៀបចចំដែនដីថ្នាក់ក្រោមជាតិ

## ៥.១ ការកសាងផែនការដោយមានការចូលរួម

ព័ត៌មាន ការពិភាក្សា និងការចូលរួមយ៉ាងសកម្មរបស់អ្នកពាក់ព័ន្ធ គឺជាមូលដ្ឋានគ្រឹះយ៉ាងសំខាន់នៅក្នុងដំណើរការកសាងផែនការរៀបចំដែនដី។ ការចូលរួមជួយដល់ការកំណត់នូវអ្វីដែលជាបញ្ហានៃការកសាងផែនការ ធ្វើឲ្យប្រសើរឡើងដល់លទ្ធផលនៃផែនការតាមរយៈធាតុចូលមកពីគ្រប់វិស័យពាក់ព័ន្ធ និងធានាដល់ការអនុវត្តប្រកបដោយភាពស៊ីសង្វាក់គ្នា និងការគ្រប់គ្រងប្រកបដោយចំណេះដឹង និងភាពជាកម្មសិទ្ធិរបស់អ្នកពាក់ព័ន្ធ។

ព័ត៌មាន ការពិភាក្សា និងការចូលរួមជាសាធារណៈ មានបីកម្រិតសំខាន់ៗ៖

- ព័ត៌មាន ការពិភាក្សា និងការចូលរួមស្ថាប័នវិស័យសាធារណៈ គឺវាមានសារៈសំខាន់ណាស់។ នេះសំដៅដល់ទាំងស្ថាប័នជំនាញរបស់រដ្ឋដែលអនុវត្តគោលនយោបាយរាជរដ្ឋាភិបាលកម្ពុជា និងអាជ្ញាធរដែនដី ដែលមានអាណត្តិក្នុងការធ្វើការសម្របសម្រួលលើកិច្ចការអភិវឌ្ឍន៍នៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។ ភាគីទាំងពីរនេះ ត្រូវធ្វើការសម្របសម្រួល និងស្វែងរកនូវតុល្យភាពនៃផលប្រយោជន៍ពីផែនការរៀបចំដែនដី។ ទន្ទឹមនឹងនេះដែរ ភាគីទាំងពីរនេះ ក៏មានតួនាទីផ្សារភ្ជាប់ដំណើរការកសាងផែនការទៅនឹងវិស័យឯកជនដែលសកម្មភាពរបស់ខ្លួនមានសារៈសំខាន់ជួយដល់ការអភិវឌ្ឍ។
- គួរធ្វើការយកចិត្តទុកដាក់ជាពិសេសចំពោះសំលេងរបស់សហគមន៍ និងសមាគមរបស់ពួកគេ។ ចំណេះដឹងដែលកើតចេញពីការពិភាក្សាជាមួយសហគមន៍ គឺជាផ្នែកមួយដ៏សំខាន់ក្នុងការរៀបចំក្របខ័ណ្ឌផែនការរៀបចំដែនដី។ ប្រសិនបើធ្វើផែនការនៅកម្រិតកាន់តែថ្នាក់ទាប នោះកាន់តែទាមទារឲ្យមានការបញ្ចូលឲ្យបានលំអិត ឲ្យបានច្បាស់លាស់ និងភ្ជាប់ថ្នាក់មូលដ្ឋានទៅក្នុងដំណើរការកសាងផែនការ។ ប្រសិនបើធ្វើផែនការនៅកម្រិតកាន់តែថ្នាក់ខ្ពស់ នោះកាន់តែទាមទារចាំបាច់នូវការគិតគូរពិចារណាក្នុងការកំណត់សមាសភាគអ្នកតំណាងក្នុងដំណើរការកសាងផែនការ ដែលអ្នកតំណាងទាំងនោះជាអ្នកដែលអាចធានាថាក្រុមអ្នកពាក់ព័ន្ធផ្សេងៗ អាចមានឱកាសបញ្ចេញមតិនៅក្នុងដំណើរការកសាងផែនការកម្រិតខ្ពស់នេះ។ សហគមន៍មិនមែនគ្រាន់តែជាក្រុមគោលដៅនោះទេ ប៉ុន្តែត្រូវបានចាត់ទុកជាដៃគូកសាងផែនការដ៏ពិតប្រាកដ។
- ព័ត៌មាន ការពិភាក្សា និងការចូលរួមរបស់អ្នកពាក់ព័ន្ធ ក៏មានសារៈសំខាន់ផងដែរ។ អង្គការអន្តរ-ជាតិ អង្គការជាតិ និងអង្គការមូលដ្ឋានរួមទាំងវិទ្យាស្ថានស្រាវជ្រាវចូលរួមនូវចំណេះដឹងនិងបណ្តាញទំនាក់ទំនងនៅក្នុងដំណើរការកសាងផែនការ និងគាំទ្រដល់ការអនុវត្តផែនការតាមរយៈធនធាននិងគម្រោង និងកម្មវិធីរបស់ខ្លួនដែលស្របទៅនឹងផែនការរៀបចំដែនដីនេះ។ ការចូលរួមរបស់វិស័យ

ឯកជន (សហគ្រាសខ្នាតតូច ធម្យម និងធំ សមាគមដូចជាសភាពាណិជ្ជកម្ម និងអ្នកផ្សេងៗទៀត) ជួយដល់ការកំណត់តម្រង់ទិសដល់យុទ្ធសាស្ត្រសេដ្ឋកិច្ចមូលដ្ឋានឲ្យចំសក្តានុពលមូលដ្ឋាន និងតម្រូវការ និងជួយលើកស្ទួយសក្តានុពលវិស័យឯកជនក្នុងការគាំទ្រដល់ការអនុវត្តផែនការ។ វាក៏ជួយកាត់បន្ថយហានិភ័យ ក្នុងករណីដែលដំណើរកសាងផែនការ អាចនឹងបង្កើតឲ្យមានទំនាស់ផលប្រយោជន៍កាន់តែច្រើន ដោយការចូលរួមនេះត្រូវធ្វើការពិភាក្សា និងសម្របសម្រួលរវាងអ្នកពាក់ព័ន្ធដែលមានផលប្រយោជន៍ទាំងអស់ក្នុងកំឡុងពេលដំណើរការកសាងផែនការ ដើម្បីឈានទៅរកការឯកភាពជារួមមួយរវាងអ្នកពាក់ព័ន្ធទាំងអស់។ ការចូលរួមនៅក្នុងដំណើរការកសាងផែនការ បានដើរតួរជាអ្នកផ្តល់ព័ត៌មានផង និងជាអ្នកទទួលព័ត៌មានផង នេះជាការឆ្លុះបញ្ចាំងឲ្យឃើញថាផែនការរៀបចំដែនដី គឺជាដំណើរការតាមបែបលទ្ធិប្រជាធិបតេយ្យសម្រាប់ការអភិវឌ្ឍ។

### ៥.២ ការកសាងផែនការបែបសមាហរណកម្ម

ផែនការរៀបចំដែនដី គឺជាដំណើរការសមាហរណកម្ម ដែលមានការចូលរួមពីតួអង្គសំខាន់ៗ គោលនយោបាយ និងផែនការ សក្តានុពល និងតម្រូវការមកពីវិស័យផ្សេងៗ (សមាហរណកម្មខ្សែទទឹង) និងមកពីរដ្ឋបាលកម្រិតផ្សេងៗគ្នា (សមាហរណកម្មខ្សែបណ្តោយ)។ វាផ្តោតជាពិសេសទៅលើភាពស៊ីសង្វាក់គ្នានៃគោលនយោបាយតាមវិស័យ ដែលមានផលប៉ះពាល់ជាក់លាក់ទៅលើដែនដី។ វាគួរធានាដល់ទំនាក់ទំនងដ៏រឹងមាំរបស់ដែនដី និងជៀសវាងនូវបញ្ហាផ្សេងៗ ដូចជាការរួបរួមគ្នាមិនពេញលេញ ប្រសិទ្ធភាពនៃការចាត់ចែងធនធានមិនបានល្អប្រសើរ និងផលិតភាពនៅក្នុងដែនដីមានផលប៉ះពាល់រាំងដល់ការប៉ាន់ប្រមាណលើការអភិវឌ្ឍដែនដីតាមការចង់បាន។ ការសម្របសម្រួល និងធ្វើសមាហរណកម្មរវាងវិស័យសំខាន់ៗទាំងអស់ គឺជាកិច្ចការងារស្មុគស្មាញមួយដ៏សំខាន់ ហើយវាក៏ជាបញ្ហាប្រឈមដ៏សំខាន់មួយផងដែរចំពោះដំណើរការកសាងផែនការរៀបចំដែនដី ដែលអាចមានផលប៉ះពាល់ជាយថាហេតុទៅលើផែនការ។

ជាមួយគ្នានេះដែរ វាមានសារៈសំខាន់ណាស់ដែលស្ថាប័នទទួលខុសត្រូវលើដំណើការកសាងផែនការរៀបចំដែនដីថ្នាក់ក្រោមជាតិ ត្រូវបានធ្វើសមាហរណកម្មយ៉ាងល្អប្រសើរទៅក្នុងអភិបាលកិច្ចថ្នាក់ក្រោមជាតិ។ បន្ថែមទៅលើគណៈកម្មាធិការទាំងបីដែលមានស្រាប់ដែលបានបង្កើតឡើងនៅក្នុងរដ្ឋបាលឯកភាព ក្រុមប្រឹក្សាអាចបង្កើតនូវគណៈកម្មាធិការបន្ថែមទៀតទៅតាមការចាំបាច់ដើម្បីជួយកិច្ចការរបស់ខ្លួន។ ស្របជាមួយនឹងគោលការណ៍នេះ អនុក្រឹត្យលេខ ៧៧ បានធ្វើការគិតទុកជាមុនអំពីការបង្កើតគណៈកម្មាធិការរៀបចំដែនដី និងនគរូបនីយកម្មថ្នាក់ក្រុង ស្រុក និងថ្នាក់ខេត្ត ដែលមានសមត្ថកិច្ចទទួលខុសត្រូវលើការកសាងផែនការរៀបចំដែនដី។ គណៈកម្មាធិការនេះត្រូវបានបញ្ចូល

ទាំងស្រុងទៅក្នុងរដ្ឋបាលឯកភាព ហើយត្រូវអនុវត្តការងារក្រោមការគ្រប់គ្រងដឹកនាំរបស់ក្រុមប្រឹក្សា និងគណៈអភិបាល។

## ៥.៣ ផែនការយុទ្ធសាស្ត្រ

យុទ្ធសាស្ត្រកំណត់ពីវិធីសាស្ត្រ ឬមធ្យោបាយក្នុងការធ្វើឲ្យបានសម្រេច ឬឈានទៅដល់គោលបំណង ឬគោលដៅពិតប្រាកដ។ យុទ្ធសាស្ត្រផែនការរៀបចំដែនដី មានភាពខុសប្លែកគ្នាទៅតាមកម្រិតផែនការ ដោយយុទ្ធសាស្ត្រទាំងនេះត្រូវបង្កើតឡើងទៅតាមកម្រិតផែនការរបស់ខ្លួន ទោះបីជាយ៉ាងណាក៏ដោយ យុទ្ធសាស្ត្រទាំងនេះត្រូវបានបង្កើតឡើងប្រកបដោយភាពច្បាស់លាស់ត្រឹមត្រូវ ហើយអាចអនុវត្តបានសម្រាប់ការអភិវឌ្ឍដែនដី។ យុទ្ធសាស្ត្រផ្តោតទៅលើការចាត់ចែង រៀបចំ និងតម្រង់ទិសដល់ការអភិវឌ្ឍតាមវិស័យនានាក្នុងទម្រង់បរិបទមួយប្រកបដោយសុទិដ្ឋិនិយម និងមានភាពស៊ីគ្នាក្នុងដែនដី ដែលឆ្លើយតបទៅនឹងសក្តានុពល និងតម្រូវការមូលដ្ឋាន និងស្របជាមួយនឹងគោលការណ៍ណែនាំរបស់គោលនយោបាយពីថ្នាក់ជាតិ។ ដូចនេះហើយ យុទ្ធសាស្ត្រធ្វើការបង្ហាញផ្លូវសំដៅដល់ការអភិវឌ្ឍដែនដីតាមក្តីប្រាថ្នា និងផ្អែកទៅលើសមាហរណកម្មជាប្រព័ន្ធជាមួយវិស័យ ផែនការ និងកម្មវិធីអភិវឌ្ឍន៍។ អាជ្ញាធរថ្នាក់ក្រោមជាតិ ជាសមាសភាគយ៉ាងសំខាន់នៅក្នុងកិច្ចការអភិបាលកិច្ចក្នុងការអភិវឌ្ឍដែនដីរបស់ខ្លួនប្រកបដោយភាពជោគជ័យ និងចីរភាព និងដោយការចូលរួម។

## ៥.៤ ប្រសិទ្ធភាពផ្នែកច្បាប់នៃផែនការរៀបចំដែនដី

ដូចដែលបានរៀបរាប់ហើយ ផែនការរៀបចំដែនដី មានយុទ្ធសាស្ត្រដែលមានភាពខុសប្លែក ឬញែកចេញពីគ្នាទៅតាមកម្រិតផែនការរបស់ខ្លួន។ ជាទូទៅ ផែនការរៀបចំដែនដី ត្រូវបានគាំទ្រដោយអាជ្ញាធរមូលដ្ឋានដែលមានអាណត្តិ (តួនាទី) ក្នុងការអភិវឌ្ឍដែនដីរបស់ខ្លួន ហើយផែនការនេះត្រូវអនុម័តដោយគណៈកម្មាធិការអន្តរក្រសួងនៅថ្នាក់លើ។ ជាលទ្ធផល ផែនការ និងគម្រោងទាំងអស់របស់មូលដ្ឋាន ឬស្ថាប័នជំនាញ ត្រូវតែស្របជាមួយនឹងផែនការរៀបចំដែនដី ហើយផែនការ និងគម្រោងទាំងនោះ គឺជាមធ្យោបាយដ៏សំខាន់ដែលគាំទ្រដល់ការអនុវត្តផែនការរៀបចំដែនដី។ ដូច្នេះផែនការរៀបចំដែនដីទាំងអស់ បានផ្សារភ្ជាប់ជាមួយនឹងរដ្ឋបាលដែលពាក់ព័ន្ធទាំងអស់ ទោះបីជាវាមិនផ្សារភ្ជាប់ជាមួយនឹងប្រជាពលរដ្ឋ ឬវិស័យឯកជនដោយផ្ទាល់ក៏ដោយ។

ជាលទ្ធផល ទោះបីជាយ៉ាងណាក៏ដោយ ផែនការរៀបចំដែនដី ក៏ផ្តល់ផលវិបាកផ្នែកផ្លូវច្បាប់ដែលត្រូវគោរពតាមដោយប្រជាពលរដ្ឋ និងវិស័យឯកជន តាមរយៈភ្នាក់ងារដែលអនុវត្តផែនការតាមវិស័យ និងវិធានការតាមច្បាប់នានា។ ផែនការរៀបចំដែនដី មិនមែនជាផែនការដែលមានឥទ្ធិពលផ្នែកផ្លូវច្បាប់ទេ ប៉ុន្តែផែនការតាមវិស័យឬសកម្មភាពនានា នឹងមានឥទ្ធិពលផ្នែកផ្លូវច្បាប់ដែលត្រូវគោរពតាម។

នៅថ្នាក់មូលដ្ឋាន ផែនការរៀបចំដែនដី ក៏ជាឯកសារផ្លូវច្បាប់ផ្ទាល់ផងដែរ វាមិនមែនសម្រាប់តែរដ្ឋាភិបាលនោះទេ ប៉ុន្តែសម្រាប់ទាំងប្រជាពលរដ្ឋ និងវិស័យឯកជន។ ផែនការប្រើប្រាស់ដីនៅក្នុងរាជធានី ក្រុង និងមជ្ឈមណ្ឌលទីប្រជុំ ក៏មានការកំណត់បន់ដែលផ្អែកទៅលើទម្រង់ និងមុខងារលក្ខណៈពិសេសរបស់ដែនដី។ បទបញ្ញត្តិសម្រាប់ការសាងសង់ដែលជាផ្នែករបស់ផែនការប្រើប្រាស់ដីលម្អិតនៅតំបន់ទីប្រជុំជន មានប្រសិទ្ធភាពផ្នែកច្បាប់ និងត្រូវប្រើប្រាស់ក្នុងការដាក់បញ្ញត្តិលើការសាងសង់នៅក្នុងក្រុង/ទីក្រុង។ ជាមួយគ្នានឹងច្បាប់ស្តីពីការរៀបចំទឹកដី នគរូបនីយកម្ម និងសំណង់ បទបញ្ញត្តិប្រើប្រាស់ដីទាំងនេះគឺជាផ្នែកមួយនៃក្របខ័ណ្ឌច្បាប់ ដែលមានឥទ្ធិពលដោយផ្ទាល់ទៅលើការសម្រេចអនុញ្ញាតឲ្យមានការអភិវឌ្ឍនានា (ដូចជាការសាងសង់ និងការប្រើប្រាស់ដី) ដែលស្ថិតនៅក្នុងវិសាលភាពនៃផែនការរៀបចំដែនដី។

# ៦. ឯកសារយោង


Bai, Z. G., D. L. Dent, L. Olsson, and M. E. Schaepman. 2008. "Proxy global assessment of land degradation." *Soil Use and Management* no. 24:223-234. doi: 10.1111/j.1475-2743.2008.00169.x.

Baran, Eric. 2005. *Cambodian Inland Fisheries: facts, figures and context*. Penang: World Fish Center.

CEMAT. 2007. *Spatial development glossary*. Edited by Conference of Ministers responsible for Spatial/Regional Planning, *Territory and landscape, No. 2*. Strasbourg: Council of Europe Publishing.

Council for Land Policy. 2015. Land Policy ”White Paper”. Phnom Penh.

Diepart, Jean-Christophe, John Pilgrim, and Jérémie Dulioust. 2014. "Migrations." In *Atlas of Cambodia: Maps on Socio-Economic Development and Environment*, edited by Save Cambodia's Wildlife, 89-96. Phnom Penh: SCW.

Dummer, Ignas. 2008. Implementation Manual on Commune/Sangkat Land Use Planning. Final draft version. edited by Ministry of Land Management-Urban Planning-Construction.

Hansen, M. C., P. V. Potapov, R. Moore, M. Hancher, S. A. Turubanova, A. Tyukavina, D. Thau, S. V. Stehman, S. J. Goetz, T. R. Loveland, A. Kommareddy, A. Egorov, L. Chini, C. O. Justice, and J.R. G. Townshend. 2013. " High-Resolution Global Maps of 21st-Century Forest Cover Change." *Science* no. 342:850-853.

Horng, Vuthy, and David Craig. 2008. *Accountibility and Planning in Decentralised Cambodia*. Edited by Cambodian Development Resources Institute, *Working Paper No 39*: CDRI.

Ministry of Land Management, Urban Planning and Construction. 2007. Draft Guidelines on Commune Land Use Planning In support of the Commune Development Planning Process. edited by Urban Planning and Construction Ministry of Land Management.

Royal Government of Cambodia. 1994. Law on Land Management, Urban Planning and Construction.

———. 2005. Strategic Framework for Decentralization and De-Concentration Reforms.

———. 2008a. Law on Administrative Management of the Capital, Provinces, Municipalities, Districts and Khans.

———. 2008b. Sub-decree on Commune Land Use Planning. Phnom Penh.

———. 2010. *National Strategic Development Plan Update 2009-2013*. Edited by Ministry of Planning. Phnom Penh.

———. 2011. National Policy On Spatial Planning of the Kingdom of Cambodia.

———. 2012a. Royal Decree on the Establishment of the National Committee on Spatial and Urban Planning.

———. 2012b. Sub-Decree No 77 On the Establishment of the Capital, Provincial, Municipal, District and Khan Committee for Land Management and Urban Planning. Phnom Penh.

———. 2015. Sub-Decree No 42 On the Urbanization of Capital, Municipality and Towns. Phnom Penh.

Save Cambodia's Wildlife. 2014. *Atlas of Cambodia: Maps on Socio-Economic Development and Environment*. 2nd edition ed. Phnom Penh, Cambodia: Save Cambodia's Wildlife.

Seng, Vang. 2014. *Cambodia’s Agricultural Land Resources: Status and Challenges*, *Policy Brief No. 1* Phnom Penh: Development Researh Forum in Cambodia.

សៀវភៅណែនាំជាសេរីនេះ កើតចេញពីកិច្ចខិតខំប្រឹងប្រែងសប្រតិបត្តិការរវាងក្រុមការងារកសាងផែនការរៀបចំដែនដីនៅថ្នាក់ខេត្ត/ក្រុង/ស្រុក អ្នកជំនាញការ និងអ្នកធ្វើសេចក្តីសម្រេចចិត្តនៅក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និងទីប្រឹក្សាអង្គការ GIZ ។

ក្រុមអ្នករៀបរៀងនិងផ្ទៀងផ្ទាត់ជួយសម្រួលដល់ការផលិតសៀវភៅនេះឡើងរួមមាន៖ ឯកឧត្តមបណ្ឌិត **ប៉ែន សុផល** ឯកឧត្តមបណ្ឌិត **ម៉េង ប៊ុណ្ណារិទ្ធិ** **Walter Koditek**, **Jean-Christophe Diepart**, **Thomas Hänert** និង **Florian Rock** ។